# ទីក្រុងថ្មី

The New City Catechism

# ទីក្រុងថ្មី

## ៥២ សំណួរ & ចម្លើយ
## សម្រាប់ចិត្ត & គំនិតយើង

អង្គការ
សកម្មភាព
កម្ពុជា

*The New City Catechism: 52 Questions and Answers for Our Hearts and Minds*

Copyright © 2017 by The Gospel Coalition and Redeemer Presbyterian Church

Published by Crossway
a publishing ministry of Good News Publishers
Wheaton, Illinois 60187, U.S.A.

ទីក្រុងថ្មី៖ ៥២ សំណួរ & ចម្លើយសម្រាប់ចិត្ត & គំនិតយើង

រក្សាសិទ្ធិគ្រប់បែបយ៉ាង © ២០១៧ ដោយ៖ The Gospel Coalition and Redeemed Presbyterian Church

បោះពុម្ពដោយក្រុម៖ Crossway ជាព័ន្ធកិច្ចបោះពុម្ពនៃក្រុម Good News Publishers

ទីក្រុង Wheaton រដ្ឋ Illinois ៦០១៨៧ សហរដ្ឋអាមេរិក

This edition published by arrangement with Crossway.
ការបោះពុម្ពមួយនេះគឺត្រូវបានធ្វើឡើងដោយមានការព្រមព្រៀងជាមួយនឹង Crossway។

បោះពុម្ពជាភាសាខ្មែររក្សាសិទ្ធិ © ២០២១

All rights reserved.
រក្សាសិទ្ធិគ្រប់បែបយ៉ាង

បោះពុម្ពលើកទី១ ចំនួន៣.០០០ក្បាល ២០២១ នៃគ.ស.

ផលិតដោយ៖ អង្គការសកម្មភាពកម្ពុជា
resources@actioncambodia.org

បកប្រែដោយ៖ លោកគ្រូ Scott, លោកគ្រូ វែល ណាថាន, លោក ឈាង បូរ៉ា, លោក ទេព រ៉ូ, លោក ខែម បូឡុង, លោក ប៊ុន ធីម៉ូថេ

កែសម្រួលដោយ៖  កញ្ញា ជុំ ចាន់ដារ៉ា, កញ្ញា អឿង ដាលីន, លោកគ្រូ លូកា ស្មីត, អ្នកគ្រូ សេង សុខា, លោក ឯក សត្យា និងលោកស្រី ថាវ ប៊ុនរី

អ្នករចនាគម្របសៀវភៅភាសាខ្មែរ៖ លោក វែល ណាថាន

អ្នករចនាអត្ថបទភាសាខ្មែរ៖ លោក វែល ណាថាន និងលោក ទេព រ៉ូ

យើងខ្ញុំបានរក្សាអក្ខរាវិរុទ្ធនៃសម្រង់ខគម្ពីរដែលមាននៅក្នុងព្រះគម្ពីរបកប្រែចាស់ រក្សាសិទ្ធិ©ឆ្នាំ១៩៥៤ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរសញ្ញាថ្មី កែសម្រួល រក្សាសិទ្ធិ©ឆ្នាំ២០១៤, ២០១៦ (គកស) ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរដ៏វិសុទ្ធជាភាសាខ្មែរបច្ចុប្បន្ន រក្សាសិទ្ធិ©ឆ្នាំ២០០៥ (គខប) ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ រក្សាសិទ្ធិ©ឆ្នាំ២០១៤ (គគខ) ដោយព័ន្ធកិច្ចព្រះបន្ទូលនៃជីវិត, ក៏ដូចជាអសាធារណនាមមួយចំនួន ប៉ុន្តែសំណេរនៅក្នុងអត្ថបទទាំងមូលយើងខ្ញុំបានខិតខំព្យាយាមគោរពតាមអក្ខរាវិរុទ្ធនៃវចនានុក្រមខ្មែររបស់សម្តេចសង្ឃរាជ ជួន ណាត។



# សេចក្ដីផ្ដើម

ព្រះយេស៊ូវបានបង្រៀនថា៖ បើផ្ទះណាគ្មានគ្រឹះរឹងមាំទេ នោះមិនយូរមិនឆាប់ផ្ទះនោះនឹងដួលរលំជាមិនខាន។ ដូចគ្នាផងដែរ ចំពោះជំនឿគ្រីស្ទបរិស័ទ ប្រសិនបើជំនឿរបស់យើងមិនមានគ្រឹះរឹងមាំទេ នោះយើងក៏នឹងមិនអាចស៊ូទ្រាំបានឡើយ នៅពេលជួបទុក្ខលំបាក។ ដើម្បីឲ្យយើងអាចស៊ូទ្រាំបាន យើងត្រូវតែសង់ជំនឿរបស់យើង នៅលើសេចក្ដីពិតដ៏រឹងមាំនៃព្រះបន្ទូលទ្រង់!

ហេតុនេះហើយបានជា កន្លងមកនេះ មានគ្រូគង្វាលជាច្រើននាក់បាននាំគ្នាប្រើប្រាស់វិធីសាស្រ្តដ៏សាមញ្ញមួយ ដើម្បីបង្រៀនអំពីចំណុចស្នូលនៃគោលលទ្ធិជំនឿគ្រីស្ទបរិស័ទដល់អ្នកជឿថ្មីៗ។ មានឪពុកម្ដាយដែលជាគ្រីស្ទបរិស័ទជាច្រើនក៏បានប្រើប្រាស់វិធីសាស្រ្តនេះ ដើម្បីអប់រំកូនចៅពួកគាត់ផងដែរ។ ទីក្រុងថ្មី៖ ៥២ សំណួរ & ចម្លើយសម្រាប់ចិត្ត & គំនិតយើងនៃគោលលទ្ធិជំនឿគឺជាវិធីសាស្រ្តដ៏សាមញ្ញ។ តាមរយៈការប្រើប្រាស់វិធីសាស្រ្តសំណួរ-ចម្លើយខ្លីៗនេះ នោះមនុស្សទាំងអស់អាចយល់ដឹងពីចំណុចសំខាន់ៗជាច្រើននៅក្នុងព្រះគម្ពីរបន្តិចម្ដងៗបាន។

នៅឆ្នាំ ១៥២៩ អ្នកដឹកនាំគ្រីស្ទបរិស័ទដ៏ល្បីល្បាញម្នាក់ឈ្មោះលោក ម៉ាធិន លូសើរ (Martin Luther) បានពណ៌នាពីស្ថានភាពគួរឲ្យសោកស្ដាយរបស់គ្រីស្ទបរិស័ទក្នុងជំនាន់នោះនៅប្រទេសអាល្លឺម៉ង់។ គាត់បានសរសេរថា៖ «មនុស្សសាមញ្ញធម្មតា ជាពិសេសអ្នករស់នៅតាមភូមិ ស្ថិតក្នុងភាពងងឹតសូន្យសុង ទាក់ទងនឹងជំនឿគ្រីស្ទបរិស័ទ ហើយរឿងដ៏គួរឲ្យសោកស្ដាយជាងនោះទៅទៀតគឺថា ក៏មានគ្រូគង្វាលជាច្រើននាក់មិនមានជំនាញ និងសមត្ថភាព ដើម្បីជួយសមាជិកក្រុមជំនុំរបស់ខ្លួនបានទេ។ ទោះបើពួកគេបានទទួលពិធីជ្រមុជទឹក ពិធីលៀងព្រះអម្ចាស់ ហើយមិនស្គាល់ពីសេចក្ដីអធិស្ឋានរបស់ព្រះអម្ចាស់ និងគោលជំនឿគ្រីស្ទបរិស័ទ ឬបញ្ញត្តិដប់ប្រការក៏ដោយ ក៏ពួកគេនៅមានឈ្មោះថាជាគ្រីស្ទបរិស័ទដែរ។ ការនេះហើយ ដែលធ្វើឲ្យពួកគេរស់នៅដូចជាហ្វូងគោហ្វូងក្របី ឬជ្រូកដែលល្ងង់ខ្លៅ»។ នៅជំនាន់លោក ម៉ាធិន លូសើរ ក៏មានគ្រីស្ទបរិស័ទជាច្រើនដែលមិនចេះអានអក្សរ ព្រមទាំងមិនស្គាល់ពីសេចក្ដីពិតសំខាន់ៗនៅក្នុងព្រះគម្ពីរផងដែរ។ ដោយសារតែមូលហេតុនេះហើយបានជាលោក ម៉ាធិន លូសើរ ទូន្មានដល់គ្រូគង្វាល និងគ្រូបង្រៀនទាំងអស់ ឲ្យខិតខំអប់រំក្រុមជំនុំរបស់ខ្លួន ដោយប្រើប្រាស់វិធីសាស្រ្តសំណួរ-ចម្លើយខ្លីៗនេះ។

គោលបំណងរបស់អ្នកនិពន្ធកូនសៀវភៅនេះគឺ៖ ដើម្បីយកវិធីសាស្រ្តដ៏មានប្រសិទ្ធិភាពពីជំនាន់មុនមកកែសម្រួល និងប្រើប្រាស់ក្នុងសម័យបច្ចុប្បន្ននេះឡើងវិញ។ រីឯយើងដែលជាក្រុមអ្នកបកប្រែសៀវភៅនេះជាភាសាខ្មែរ យើងសង្ឃឹមថា ព្រះអម្ចាស់នឹងប្រើប្រាស់វា ដើម្បីពង្រឹងជំនឿរបស់ក្រុមជំនុំខ្មែរ គ្រប់វ័យទាំងអស់។

សូមព្រះអង្គប្រទានពរ!

## ជំនួយសម្រាប់ការចងចាំ

- សូមអានសំណួរចម្លើយឲ្យឮៗ ហើយបន្ទាប់មកធ្វើម្តងទៀតសារឡើងវិញពីរបីដង។
- សូមអានសំណួរចម្លើយឲ្យឮៗ ហើយបន្ទាប់មកព្យាយាមធ្វើសារឡើងវិញដោយមិនមើល ហើយធ្វើម្តងទៀត។
- សូមអានសំណួរចម្លើយនៃផ្នែកទី១ឲ្យឮៗ (បន្ទាប់មកផ្នែកទី២ និងទី៣) ខណៈពេលដែលបងប្អូនដើរទៅដើរមក។ ការលាយឡំការមានចលនាបំផ្លាស់ទី និងការនិយាយជួយពង្រឹងសមត្ថភាពនៃបុគ្គលណាម្នាក់ក្នុងការជួយឲ្យគាត់នឹកឃើញអត្ថបទនោះឡើងវិញបាន។
- សូមថតសំឡេងលោកអ្នកអានសំណួរចម្លើយនៃផ្នែកទី១ឲ្យឮៗ (បន្ទាប់មកផ្នែកទី២ និងទី៣) ហើយស្តាប់ការថតនោះរាល់ថ្ងៃនៅពេលដែលលោកអ្នកហាត់ប្រាណ ធ្វើកិច្ចការផ្ទះ។ល។
- សូមសរសេរសំណួរចម្លើយលើក្រដាស ហើយបិទវានៅកន្លែងដែលលោកអ្នកទៅជាញឹកញាប់។ អានសំណួរចម្លើយឲ្យឮៗរាល់ពេលដែលលោកអ្នកឃើញវា។
- សូមសរសេរសំណួរលើក្រដាសម្ខាង ហើយចម្លើយលើក្រដាសម្ខាងទៀត ហើយសាកល្បងលើខ្លួនឯង។ ក្មេងៗអាចផាត់ពណ៌ និងគូសរូបលើវាបាន។
- សូមរម្លឹកសំណួរចម្លើយនៅពេលយប់ និងនៅពេលព្រឹក។ សម្រាប់ក្មេងៗ សូមចំណាយពេលបន្តិចមុនពេលចូលគេង ដើម្បីជួយពួកគាត់ឲ្យចងចាំចម្លើយ ហើយរម្លឹកនៅពេលញ៉ាំអាហារពេលព្រឹកនៅថ្ងៃបន្ទាប់។
- សូមសរសេរសំណួរចម្លើយចុះ។ ធ្វើវាម្តងហើយម្តងទៀត។ ការសរសេរជួយពង្រឹងសមត្ថភាពនៃបុគ្គលណាម្នាក់ក្នុងការជួយឲ្យគាត់នឹកឃើញអត្ថបទនោះឡើងវិញបាន។
- ប្រសិនបើអាចធ្វើបាន ចូរសួរសំណួរចម្លើយជាមួយនឹងបុគ្គលណាម្នាក់ផ្សេងទៀត។
- សូមចូលទៅកាន់គេហទំព័រ៖ www.khmerqanda.com ដើម្បីរកឃើញធនធានមួយចំនួនទៀត។

# ការឆ្លើយតបរបស់យើងទៅកាន់ព្រះជាម្ចាស់

លោកអ្នកនឹងកត់សម្គាល់ឃើញថា រាល់សំណួរចម្លើយមានសញ្ញាសម្គាល់មួយដែលស៊ីគ្នាទៅនឹងលក្ខណសម្បត្តិរបស់គ្រីស្ទបរិស័ទនៅក្នុងទំព័រទី ១១។ រាល់សំណួរចម្លើយគឺត្រូវបានដកចេញពីព្រះបន្ទូលផ្ទាល់តែម្តង។ សញ្ញាសម្គាល់នៃលក្ខណសម្បត្តិគឺគ្រាន់តែជាជំនួយដល់គ្រូៗក្នុងការនិយាយទៅកាន់សិស្សអំពីរបៀបឆ្លើយតបទៅនឹងព្រះបន្ទូលរបស់ព្រះជាម្ចាស់ប៉ុណ្ណោះ។ ចំណុចផ្តោត និងគោលបំណងនៃកូនសៀវភៅ «ទីក្រុងថ្មី៖ ៥២ សំណួរ & ចម្លើយ សម្រាប់ចិត្ត & គំនិតយើង» គឺដើម្បីពង្រឹងសភាព និងជះឥទ្ធិពលលើដួងចិត្តរបស់អស់អ្នកដែលសិក្សា ដោយសង្ឃឹមថាសំណួរចម្លើយនឹងជួយផ្តត់ផ្គង់បានយ៉ាងល្អចំពោះការពង្រឹងភាពកោតខ្លាចព្រះជាម្ចាស់ ការពេញវ័យ និងពង្រឹងលក្ខណសម្បត្តិរបស់មនុស្សប្រុសស្រី។

យើងសង្ឃឹមថា ខណៈពេលដែលក្រុមគ្រួសារសិក្សាជាមួយគ្នានូវសំណួរចម្លើយទាំង ៥២ ក្នុងកូនសៀវភៅនេះ នោះពួកគេនឹងមិនគ្រាន់តែរីកចម្រើនក្នុងចំណេះដឹងទេ ប៉ុន្តែក្នុងផលផ្លែនៃព្រះវិញ្ញាណខណៈពេលដែលពួកគាត់កាន់តែស្រឡាញ់ព្រះជាម្ចាស់អស់ពីដួងចិត្ត។

«សេចក្តីទាំងនេះដែលខ្ញុំបង្គាប់អ្នកនៅថ្ងៃនេះ ត្រូវនៅជាប់ក្នុងចិត្តរបស់អ្នកជានិច្ច។ ត្រូវបង្រៀនសេចក្តីទាំងនេះដល់កូនចៅរបស់អ្នក ហើយត្រូវដំណាលសេចក្តីទាំងនេះ ពេលអ្នកអង្គុយនៅក្នុងផ្ទះ ពេលដើរតាមផ្លូវ ពេលដេក និងពេលក្រោកឡើងផង។ ត្រូវចងសេចក្តីទាំងនេះជាទីសម្គាល់នៅនឹងដៃ ហើយត្រូវធ្វើជាស្លាកនៅកណ្តាលថ្ងាសរបស់អ្នក ត្រូវកត់សេចក្តីទាំងនេះនៅក្របទ្វារផ្ទះ និងនៅទ្វារក្រុងរបស់អ្នក» (ចោទិយកថា ៦:៦-៩)។

– លោកស្រី Melanie Lacy
ប្រធានផ្នែកទេវវិទ្យាសម្រាប់ក្មេងៗ និងយុវជន
នៅមហាវិទ្យាល័យ Oak Hill

# គន្លឹះលក្ខណសម្បត្តិ

## ស្ញប់ស្ញែង

ខណៈពេលដែលក្មេងៗចាប់ផ្ដើមកាន់តែយល់អំពីព្រះជាម្ចាស់ នោះពួកគេនឹងយល់បានយ៉ាងត្រឹមត្រូវថា ខ្លួនគឺជាបុគ្គលដែលព្រះជាម្ចាស់បានបង្កើតមក ដើម្បីឲ្យមានទំនាក់ទំនងជាមួយនឹងទ្រង់ និងអ្នកដទៃជាមិនខាន។

## ការអត់ទោស

ខណៈពេលដែលក្មេងៗកាន់តែយល់បានយ៉ាងច្បាស់លាស់អំពីការអត់ទោសដ៏អស្ចារ្យដែលព្រះជាម្ចាស់បានប្រទានដល់ពួកគេ តាមរយៈយញ្ញបូជានៃការសុគតរបស់ព្រះគ្រីស្ទនៅលើឈើឆ្កាង នោះពួកគេក៏នឹងអភិវឌ្ឍលក្ខណៈសម្បត្តិនៃការអត់ទោសដល់អ្នកដទៃយ៉ាងសកម្មផងដែរ។

## ការដឹងគុណ

ខណៈពេលដែលក្មេងៗកាន់តែយល់អំពីសេចក្ដីសប្បុរស និងព្រះគុណរបស់ព្រះជាម្ចាស់ក្នុងជីវិតរបស់ខ្លួន នោះពួកគាត់នឹងមានបុគ្គលិកលក្ខណៈនៃការដឹងគុណជាមិនខាន។ ការនេះនាំឲ្យមានចិត្តដែលដឹងគុណ ហើយបណ្ដាលឲ្យក្មេងៗប្រព្រឹត្តក្នុងរបៀបសប្បុរសទៅកាន់អ្នកដទៃ។

## ភាពស្មោះត្រង់

ខណៈពេលដែលក្មេងៗកាន់តែយល់អំពីសេចក្ដីពិតនៃដំណឹងល្អ និងភាពបរិសុទ្ធរបស់ព្រះជាម្ចាស់ នោះពួកគាត់នឹងប្រាថ្នាចង់រស់នៅក្នុងរបៀបដែលអាចមើលឃើញជាក់នឹងភ្នែកបាន និងស្មោះត្រង់ ហើយការនេះនឹងក្លាយជាអត្ថប្រយោជន៍ដ៏ល្អក្នុងទំនាក់ទំនងរបស់ពួកគាត់ជាមួយនឹងព្រះជាម្ចាស់ និងអ្នកដទៃ។

## ក្ដីសង្ឃឹម

ខណៈពេលដែលក្មេងៗកាន់តែយល់អំពីផែនការដ៏អស់កល្បជានិច្ចរបស់ព្រះជាម្ចាស់និងការផ្គត់ផ្គង់របស់ទ្រង់  នោះពួកគាត់ក៏នឹងចាប់ផ្ដើមស្គាល់ក្ដីសង្ឃឹមដែលថា ព្រះជាម្ចាស់កំពុងតែធ្វើការក្នុងពួកគាត់ ដើម្បីឲ្យកាន់តែមានលក្ខណៈដូចជាព្រះយេស៊ូវ ហើយថាថ្ងៃមួយពួកគាត់នឹងនៅជាមួយនឹងទ្រង់យ៉ាងអស់កល្បជានិច្ចតែម្ដង។

## ការបន្ទាបខ្លួន

ខណៈពេលដែលក្មេងៗកាន់តែយល់អំពីការបន្ទាបខ្លួនដែលព្រះយេស៊ូវបានបង្ហាញឲ្យឃើញ នោះពួកគាត់នឹងកាន់តែរៀនដាក់តម្រូវការរបស់អ្នកដទៃមុនរបស់ខ្លួន។ ពួកគាត់គួររៀនស្ម័គ្រចិត្តលះបង់ការទទួលផលចំណេញផ្ទាល់ខ្លួន និងឋានៈសម្រាប់ជាប្រយោជន៍អ្នកដទៃ។

## អំណរ

ខណៈពេលដែលក្មេងៗកាន់តែស្គាល់ និងយល់អំពីភាពល្អឥតខ្ចោះ អំណាចព្រះចេស្ដា និងការផ្គត់ផ្គង់របស់ព្រះជាម្ចាស់ នោះពួកគាត់នឹងបង្កើតបុគ្គលិកលក្ខណៈនៃការមានអំណរ។ ការនេះនឹងបណ្ដាលឲ្យពួកគាត់មានភាពស្កប់ស្កល់ចិត្តក្នុងព្រះជាម្ចាស់ និងក្នុងក្ដីសន្យារបស់ទ្រង់ជាជាងលើភាពដ៏សប្បាយដែលមិននៅគង់វង្សដែលកើតចេញពីបទពិសោធន៍ និងអ្វីដែលកើតឡើងចេញពីខាងក្រៅ។

## ក្ដីស្រឡាញ់

ខណៈពេលដែលក្មេងៗកាន់តែយល់អំពីការស្រឡាញ់ដែលគ្មានលក្ខខណ្ឌរបស់ព្រះជាម្ចាស់ ដើម្បីប្រោសលោះពួកគាត់ នោះពួកគាត់នឹងកាន់តែមានសមត្ថភាពក្នុងការស្រឡាញ់ និងទំនោរនៃការស្រឡាញ់ហើយក៏នឹងកាន់តែរីកចម្រើនឡើង ហើយជះឥទ្ធិពលលើទំនាក់ទំនងក្នុងក្រុមគ្រួសារ និងមិត្តភក្ដិខ្លួនជាមិនខាន។

## សេចក្ដីទ្រាំទ្រ

ខណៈពេលដែលក្មេងៗកាន់តែយល់អំពីព័ន្ធកិច្ចរបស់ព្រះវិញ្ញាណក្នុងជីវិតរបស់ខ្លួន និងក្ដីសង្ឃឹមនៃសិរីល្អដ៏នៅអស់កល្បជានិច្ច នោះពួកគាត់នឹងលូតលាស់ខាងឯការមានចិត្តទ្រាំទ្រ។ ពួកគាត់នឹងមានមូលដ្ឋានគ្រឹះ ដើម្បីប្រឈមមុខនឹងទុក្ខលំបាក និងភាពវេទនានៃជីវិតដោយមានទំនុកចិត្តលើអំណាច និងការផ្គត់ផ្គង់របស់ព្រះជាម្ចាស់។

## ការទុកចិត្ត

ខណៈពេលដែលក្មេងៗរៀនអំពីសេចក្ដីពិតនៃព្រះត្រៃឯក និងព្រះបន្ទូល នោះពួកគាត់នឹងបង្កើតឲ្យមានទស្សនៈយ៉ាងមាំមួន និងគួរឲ្យទុកចិត្តបាននៅពេលដែលពួកគាត់ប្រឈមមុខនឹងលោកីយ៍នេះ។

សំណួរមានពុម្ពអក្សរធំដែលងាយស្រួលអានឲ្យឆាប់ចប់។

សំណួរទី២៤

# ហេតុអ្វីបានជាព្រះគ្រីស្ទ ដែលជាព្រះដ៏ប្រោសលោះ ចាំបាច់ត្រូវសុគត?



រូបភាពដែលមានក្នុងសៀវភៅនេះគឺជាគំនូសដែលអាចមើលឃើញអំពីសំណួរចម្លើយ។ រូបភាពនីមួយៗត្រូវបានរចនាឡើង ដើម្បីជាជំនួយដល់អស់អ្នកដែលរៀនតាមបែបមើលឃើញពេលទន្ទេញឲ្យចងចាំ។

ចម្លើយ៖

ដោយសារសេចក្តីស្លាប់គឺជាទណ្ឌកម្មនៃអំពើបាប ដូច្នេះ ព្រះគ្រីស្ទបានសុគ្រព្រះទ័យសុគតជំនួសយើង ដើម្បីរំដោះយើងចេញពីអំណាច និងការដាក់ទោសនៃអំពើបាប ហើយនាំយើងទៅឯព្រះជាម្ចាស់វិញ។ តាមរយៈការសុគតរបស់ទ្រង់ដែលធួននឹងបាបជំនួសយើង នោះមានតែព្រះអង្គតែមួយប៉ុណ្ណោះទេ ដែលអាចរំដោះយើងឲ្យរួចពីស្ថាននរក ហើយទទួលបាននូវការអត់ទោសបាប សេចក្តីសុចរិត និងជីវិតអស់កល្បជានិច្ចសម្រាប់យើង។

កន្លែងដែលអក្សរមានពណ៌គឺជាចម្លើយដ៏ខ្លី ដែលយើងបានរចនាឡើងសម្រាប់ឲ្យក្មេងៗដែលមានអាយុតិចរៀនចងចាំ។

សញ្ញាសម្គាល់នេះតំណាងឲ្យការឆ្លើយតបទៅកាន់ព្រះជាម្ចាស់ដែលកើតចេញពីសំណួរនីមួយៗ។ បងប្អូនក៏អាចរកឃើញសញ្ញាសម្គាល់នេះនៅក្នុងទំព័រទី ១១ ផងដែរ។

ខគម្ពីរយោង

**កូឡូស ១:២១-២២**
រីឯអ្នករាល់គ្នា ដែលពីដើមត្រូវឃ្លាតឆ្ងាយ ហើយជាខ្មាំងសត្រូវក្នុងគំនិត ដោយសារអំពើអាក្រក់ ឥឡូវនេះ ព្រះអង្គបានផ្សះផ្សាក្នុងរូបសាច់ព្រះអង្គ ដោយបានទទួលសុគត ដើម្បីថ្វាយអ្នករាល់គ្នាជាតង្វាយបរិសុទ្ធ ឥតសៅហ្មង ហើយឥតកន្លែងបន្ទោសបាន នៅចំពោះព្រះអង្គ (គកស)។

ផ្នែកទី១

# ព្រះជាម្ចាស់ ការបង្កើតពិភពលោក ការធ្លាក់ក្នុងអំពើបាប និងក្រឹត្យវិន័យ

សំណួរទី១

# តើអ្វីទៅជាក្តីសង្ឃឹមតែមួយគត់របស់យើងនៅក្នុងជីវិតនេះ និងនៅពេលដែលយើងស្លាប់ទៅ?



ចម្លើយ៖

យើងមិនមែនជាម្ចាស់ខ្លួនយើងទេ ប៉ុន្តែទាំងរូបកាយ និងព្រលឹងទាំងពេលនៅរស់ និងពេលស្លាប់ជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់ និងព្រះយេស៊ូវគ្រីស្ទដែលជាព្រះអង្គសង្គ្រោះរបស់យើង។

**រ៉ូម ១៤:៧-៨**

ដ្បិតក្នុងចំណោមយើង គ្មានអ្នកណារស់សម្រាប់ខ្លួនឯងទេ ហើយក៏គ្មានអ្នកណាស្លាប់សម្រាប់ខ្លួនឯងដែរ ប្រសិនបើយើងរស់ យើងរស់ដើម្បីព្រះអម្ចាស់ ហើយប្រសិនបើយើងស្លាប់ ក៏ស្លាប់ដើម្បីព្រះអម្ចាស់។ ដូច្នេះ ទោះជាយើងរស់ ឬស្លាប់ក្តី ក៏យើងជារបស់ព្រះអម្ចាស់ដែរ។

សំណួរទី២

# តើព្រះជានរណា?



ចម្លើយ៖

ព្រះគឺជាព្រះអាទិករ និងជាព្រះទ្រទ្រង់នៃមនុស្សគ្រប់ៗគ្នា និងរបស់សព្វសារពើ។ ព្រះអង្គគង់នៅអស់កល្បជានិច្ច ហើយក៏គ្មានការចាប់ផ្តើម ឬក៏ទីបញ្ចប់ដែរ។ ព្រះចេស្តា ភាពគ្រប់លក្ខណ៌ សេចក្តីសប្បុរស សិរីល្អ ព្រះប្រាជ្ញាញាណ សេចក្តីយុត្តិធម៌ និងសេចក្តីពិតរបស់ទ្រង់ គឺគ្មានការប្រែប្រួលឡើយ។ គ្មានអ្វីមួយកើតឡើងបានឡើយលើកលែងតែតាមរយៈទ្រង់ និងស្របតាមព្រះហឫទ័យទ្រង់។

**ទំនុកតម្កើង ៨៦:៨-១០, ១៥**

ឱព្រះអម្ចាស់អើយ ក្នុងចំណោមព្រះទាំងឡាយ គ្មានព្រះណាដូចព្រះអង្គទេ ក៏គ្មានព្រះណាធ្វើការអស្ចារ្យដូចព្រះអង្គឡើយ។ ឱព្រះអម្ចាស់អើយ អស់ទាំងសាសន៍ដែលព្រះអង្គបានបង្កើត នឹងនាំគ្នាមកក្រាបថ្វាយបង្គំព្រះអង្គ ហើយនឹងលើកតម្កើងព្រះនាមព្រះអង្គ។ ដ្បិតព្រះអង្គធំ ហើយធ្វើការយ៉ាងអស្ចារ្យមានតែព្រះអង្គប៉ុណ្ណោះដែលជាព្រះ...ឱព្រះអម្ចាស់អើយ ព្រះអង្គជាព្រះប្រកបដោយព្រះហឫទ័យមេត្តា និងប្រណីសន្តោស ព្រះអង្គយឺតនឹងខ្ញាល់ ហើយមានព្រះហឫទ័យសប្បុរស និងព្រះហឫទ័យស្មោះត្រង់ជាបរិបូរ (គកស)។

សំណួរទី៣

# តើក្នុងព្រះមានបុគ្គល ប៉ុន្មានអង្គ?

ចម្លើយ៖

មានបុគ្គលបីអង្គក្នុងព្រះពិតតែមួយដែលមានព្រះជន្មគង់នៅគឺ៖ ព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ។ បុគ្គលទាំងបីអង្គមានលក្ខណៈដូចគ្នា ហើយស្មើគ្នាទាំងក្នុងអំណាចព្រះចេស្ដា និងសិរីល្អ។

**២កូរិនថូស ១៣:១៤**

សូមឲ្យអ្នករាល់គ្នាបានប្រកបដោយព្រះគុណរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ និងសេចក្តីស្រឡាញ់របស់ព្រះ ព្រមទាំងសេចក្តីប្រកបរបស់ព្រះវិញ្ញាណបរិសុទ្ធ។ អាម៉ែន (គកស)។

សំណួរទី៤

# តើព្រះបានបង្កើតមនុស្ស យ៉ាងដូចម្ដេច និងក្នុងគោលបំណងអ្វី?



ចម្លើយ៖

ព្រះជាម្ចាស់បានបង្កើតមនុស្សយើងជាប្រុស និងជាស្រីក្នុងរូបដូចអង្គទ្រង់ ដើម្បីឲ្យស្គាល់ទ្រង់ស្រឡាញ់ទ្រង់ រស់នៅជាមួយនឹងទ្រង់ និងថ្វាយសិរីល្អដល់ទ្រង់។ ហើយការដែលយើងរស់នៅ ដើម្បីថ្វាយសិរីល្អដល់ព្រះអង្គ នោះជាការដ៏ត្រឹមត្រូវណាស់ ព្រោះយើងជាស្នាព្រះហស្តរបស់ទ្រង់។

**លោកុប្បត្តិ ១:២៧**

ព្រះជាម្ចាស់ បានបង្កើតមនុស្ស ជាតំណាងរបស់ព្រះអង្គ ព្រះអង្គបានបង្កើតគេឲ្យមានលក្ខណៈដូចព្រះ ជាម្ចាស់ ព្រះអង្គបានបង្កើតគេជាបុរស ជាស្ត្រី។

សំណួរទី៥

# តើព្រះបានបង្កើតអ្វីផ្សេងទៀតមក?



## ចម្លើយ៖

ព្រះបានបង្កើតរបស់សព្វសារពើទាំងអស់ដោយប្រើព្រះបន្ទូលដែលមានពេញដោយអំណាចព្រះចេស្ដារបស់ទ្រង់។ ហើយអ្វីៗដែលទ្រង់បានបង្កើតមកនោះសុទ្ធតែល្អប្រពៃណាស់។ អ្វីៗគ្រប់យ៉ាងដែលព្រះបានបង្កើតក៏បានលូតលាស់ក្រោមការគ្រប់គ្រងរបស់ព្រះអង្គដែលមានពេញទៅដោយសេចក្ដីស្រឡាញ់។

**លោកុប្បត្តិ ១:៣១**

ព្រះទ្រង់ទតអ្វីៗទាំងអស់ដែលព្រះអង្គបានបង្កើតមក ឃើញថាល្អប្រពៃណាស់ (គកស)។

សំណួរទី៦

# តើយើងអាចថ្វាយសិរីល្អ ដល់ព្រះជាម្ចាស់បានដោយ របៀបណា?

ចម្លើយ៖

យើងអាចថ្វាយសិរីល្អដល់ព្រះអង្គតាមរយៈការអរសប្បាយជាមួយទ្រង់ ការស្រឡាញ់ទ្រង់ ជឿទុកចិត្តលើទ្រង់ និងតាមរយៈការស្តាប់បង្គាប់តាមព្រះហឫទ័យ បញ្ញត្តិ និងក្រឹត្យវិន័យរបស់ទ្រង់។

**ចោទិយកថា ១១:១**

ដូច្នេះ ត្រូវស្រឡាញ់ព្រះយេហូវ៉ាជាព្រះរបស់អ្នក ហើយកាន់តាមបញ្ញា ច្បាប់ បញ្ញត្តិ និងសេចក្ដីបង្គាប់របស់ព្រះអង្គជានិច្ច (គកស)។

សំណួរទី៧

# តើក្រឹត្យវិន័យរបស់ព្រះជាម្ចាស់ទាមទារអ្វីខ្លះ?



ចម្លើយ៖

ក្រឹត្យវិន័យរបស់ព្រះអង្គទាមទារឲ្យយើងម្នាក់ៗស្តាប់បង្គាប់ទ្រង់ឲ្យបានគ្រប់លក្ខណ៍ ហើយគ្រប់ពេលវេលា គឺឲ្យយើងត្រូវស្រឡាញ់ទ្រង់ឲ្យអស់ពីចិត្ត អស់ពីព្រលឹង អស់ពីគំនិត និងអស់ពីកម្លាំង ហើយឲ្យស្រឡាញ់អ្នកជិតខាងដូចស្រឡាញ់ខ្លួនឯង។ អ្វីៗដែលព្រះអង្គហាមប្រាម យើងមិនត្រូវប្រព្រឹត្តឡើយ ហើយអ្វីៗដែលទ្រង់បង្គាប់ឲ្យធ្វើ យើងត្រូវប្រព្រឹត្តជានិច្ចវិញ។

**ម៉ាថាយ ២២:៣៧-៤០**

ព្រះអង្គមានព្រះបន្ទូលទៅគាត់ថា៖ «“ត្រូវស្រឡាញ់ព្រះអម្ចាស់ ជាព្រះរបស់អ្នក ឲ្យអស់ពីចិត្ត អស់ពីព្រលឹង និងអស់ពីគំនិតរបស់អ្នក” នេះជាបទបញ្ជាទីមួយ ហើយសំខាន់ជាងគេ។ ហើយបទបញ្ជាទីពីរក៏សំខាន់ដូចគ្នា គឺ “ត្រូវស្រឡាញ់អ្នកជិតខាងរបស់អ្នកដូចខ្លួនឯង” គ្រប់ទាំងគម្ពីរក្រឹត្យវិន័យ និងគម្ពីរហោរាមានឫសគល់ចេញពីបទបញ្ជាទាំងពីរនេះឯង» (គកស)។

សំណួរទី៨

# តើក្រឹត្យវិន័យទាំងដប់ប្រការរបស់ព្រះជាម្ចាស់មានចែងឡើងយ៉ាងដូចម្ដេចខ្លះ?



ចម្លើយ៖

មិនត្រូវគោរពព្រះឯណាផ្សេង ក្រៅពីអញឡើយ។ មិនត្រូវឆ្លាក់រូបអ្វី ឬយកវត្ថុណាមួយ ដែលជាតំណាងអ្វីមួយនៅលើមេឃ នៅក្រោមផែនដី ឬនៅក្នុងទឹក យកមកធ្វើជាព្រះ មិនត្រូវឱនក្រាប ឬថ្វាយបង្គំរូបព្រះទាំងនោះឡើយ។ មិនត្រូវយកព្រះនាមរបស់ព្រះអម្ចាស់ជាព្រះរបស់ឯងទៅប្រើប្រាស់ដោយឥតបានការនោះទេ។ ចូរនឹកចាំពីថ្ងៃសប្ប័ទ ហើយញែកថ្ងៃនោះទុកជាថ្ងៃដ៏បរិសុទ្ធ។ ចូរគោរពមាតាបិតារបស់ខ្លួន។ កុំសម្លាប់មនុស្ស។ កុំប្រព្រឹត្តអំពើផិតក្បត់។ កុំលួចប្លន់ឡើយ។ កុំធ្វើជាសាក្សីក្លែងក្លាយ។ កុំលោភចង់បានរបស់អ្នកដទៃឲ្យសោះ។

**និក្ខមនំ ២០:៣**

មិនត្រូវមានព្រះណាផ្សេងនៅចំពោះយើងឡើយ (គកស)។

សំណួរទី៩

# តើព្រះជាម្ចាស់ទាមទារឲ្យយើងធ្វើអ្វីខ្លះនៅក្នុងក្រឹត្យវិន័យទី១ ទី២ និងទី៣?



ចម្លើយ៖

នៅក្នុងក្រឹត្យវិន័យទី១ ទ្រង់ទាមទារឲ្យយើងស្គាល់ និងជឿទុកចិត្តលើព្រះអង្គដែលជាព្រះដ៏ពិតតែមួយគត់ និងជាព្រះដែលមានព្រះជន្មគង់នៅ។ នៅក្នុងក្រឹត្យវិន័យទី២ ទ្រង់ទាមទារឲ្យយើងគេចចេញពីការថ្វាយបង្គំព្រះក្លែងក្លាយនានា ហើយកុំឲ្យថ្វាយបង្គំព្រះអង្គក្នុងបែបមិនត្រឹមត្រូវ។ នៅក្នុងក្រឹត្យវិន័យទី៣ ទ្រង់ទាមទារឲ្យយើងមានការកោតខ្លាច និងគោរពដល់ព្រះនាមទ្រង់ ហើយថ្វាយព្រះកិត្តិយសដល់ព្រះបន្ទូល និងព្រះរាជកិច្ចនានារបស់ផងទ្រង់ដែរ។

**ចោទិយកថា ៦:១៣-១៤**

ត្រូវកោតខ្លាចដល់ព្រះយេហូវ៉ាជាព្រះនៃឯង ហើយគោរពប្រតិបត្តិដល់ទ្រង់ ព្រមទាំងស្បថដោយនូវព្រះនាមទ្រង់ មិនត្រូវឲ្យឯងរាល់គ្នាទៅតាមព្រះឯណាទៀត ក្នុងពួកព្រះរបស់សាសន៍ទាំងប៉ុន្មានដែលនៅជុំវិញឯងឡើយ។

សំណួរទី១០

# តើព្រះជាម្ចាស់ទាមទារឲ្យយើងធ្វើអ្វីខ្លះនៅក្នុងក្រឹត្យវិន័យទី៤ និងទី៥?



ចម្លើយ៖

នៅក្នុងក្រឹត្យវិន័យទី៤ នៅថ្ងៃសប្ប័ទ ទ្រង់ទាមទារឲ្យយើងចំណាយពេលថ្វាយបង្គំព្រះជាសាធារណៈ និងតែម្នាក់ឯង ទាំងសម្រាកពីការងារប្រចាំថ្ងៃ បម្រើព្រះអម្ចាស់ និងអ្នកដទៃ ដែលបង្ហាញថាយើងកំពុងរង់ចាំថ្ងៃសប្ប័ទដ៏នៅអស់កល្បដែលនឹងមកដល់។ នៅក្នុងក្រឹត្យវិន័យទី៥ ទ្រង់ទាមទារឲ្យយើងស្រឡាញ់ និងផ្តល់កិត្តិយសដល់ឪពុកម្តាយយើង ដោយស្តាប់បង្គាប់តាមវិន័យ និងការណែនាំរបស់ពួកគាត់ដែលស្របតាមបំណងព្រះហឫទ័យព្រះ។

**លេវីវិន័យ ១៩:៣**

អ្នករាល់គ្នាត្រូវកោតខ្លាចឪពុកម្តាយអ្នករៀងខ្លួន ហើយរក្សាថ្ងៃសប្ប័ទរបស់យើងដែរ យើងនេះហើយជាយេហូវ៉ា ជាព្រះរបស់អ្នករាល់គ្នា (គកស)។

សំណួរទី១១

# តើព្រះជាម្ចាស់ទាមទារឲ្យយើងធ្វើអ្វីខ្លះនៅក្នុងក្រឹត្យវិន័យទី៦ ទី៧ និងទី៨?



ចម្លើយ៖

នៅក្នុងក្រឹត្យវិន័យទី៦ ទ្រង់ទាមទារឲ្យយើងមិនស្អប់ ឬរករឿងអ្នកជិតខាងយើង ព្រមទាំងមិនធ្វើឲ្យពួកគេឈឺចាប់ តែផ្ទុយទៅវិញយើងត្រូវចេះអត់ធ្មត់ និងរស់នៅដោយសុខសាន្ត ហើយតាមស្រឡាញ់សូម្បីតែខ្មាំងសត្រូវរបស់យើងក៏ដោយ។ នៅក្នុងក្រឹត្យវិន័យទី៧ ទ្រង់ទាមទារឲ្យយើងត្រូវចៀសចេញពីអំពើអសីលធម៌ខាងឯផ្លូវភេទ ហើយរស់នៅដោយបរិសុទ្ធ និងស្មោះត្រង់ មិនថាក្នុងជីវិតអាពាហ៍ពិពាហ៍ ឬក៏ជីវិតនៅលីវក្តី។ ដែលនេះមានន័យថាយើងត្រូវចៀសចេញពីអំពើសៅហ្មង ការមើល ការនិយាយស្តី ការគិតគូរ សេចក្តីប្រាថ្នា ឬក៏អ្វីផ្សេងទៀតដែលអាចនាំយើងទៅរកភាពអសីលធម៌។ នៅក្នុងក្រឹត្យវិន័យទី៨ ទ្រង់ទាមទារមិនឲ្យយើងយករបស់អ្នកដទៃដោយគ្មានការអនុញ្ញាត ឬក៏មិនធ្វើអ្វីមួយដែលល្មើសដល់នរណាម្នាក់នៅពេលដែលយើងមានឱកាស។

**រ៉ូម ១៣:៩**

ព្រោះមានសេចក្តីចែងទុកមកថា «កុំប្រព្រឹត្តអំពើផិតក្បត់ កុំសម្លាប់មនុស្ស កុំលួចទ្រព្យសម្បត្តិគេ កុំមានចិត្តលោភលន់» ព្រមទាំងមានបទបញ្ញាឯទៀតដែលសរុបមកក្នុងពាក្យតែមួយនេះថាៈ «ចូរស្រឡាញ់បងប្អូនឯទៀតៗ ឲ្យបានដូចស្រឡាញ់ខ្លួនឯងដែរ» (គខប)។

សំណួរទី១២

# តើព្រះជាម្ចាស់ទាមទារឲ្យយើងធ្វើអ្វីខ្លះនៅក្នុងក្រឹត្យវិន័យទី៩ និងទី១០?



ចម្លើយ៖

នៅក្នុងក្រឹត្យវិន័យទី៩ ទ្រង់ទាមទារមិនឲ្យយើងនិយាយកុហកភូតភរ ឬបោកបញ្ឆោតអ្នកដទៃ តែនិយាយសេចក្ដីពិតដោយសេចក្ដីស្រឡាញ់វិញ។ នៅក្នុងក្រឹត្យវិន័យទី១០ ទ្រង់ទាមទារឲ្យយើងមានចិត្តស្កប់ស្កល់ និងមិនត្រូវច្រណែនឈ្នានីសចំពោះអ្នកណាម្នាក់ ឬក៏តូចចិត្តចំពោះអ្វីៗ ដែលព្រះអង្គបានប្រទានដល់ពួកគេ ឬដល់យើងឡើយ។

**យ៉ាកុប ២:៨**

ប្រសិនបើអ្នករាល់គ្នាកាន់តាមក្រឹត្យវិន័យ ដូចមានចែងក្នុងបទគម្ពីរថា៖ «ចូរស្រឡាញ់អ្នកជិតខាងរបស់អ្នកដូចខ្លួនឯង» នោះអ្នកប្រព្រឹត្តបានល្អប្រសើរហើយ (គកស)។

សំណួរទី១៣

# តើមានអ្នកណាម្នាក់អាចប្រតិបត្តិតាមក្រឹត្យវិន័យរបស់ព្រះជាម្ចាស់បានយ៉ាងល្អឥតខ្ចោះដែរឬទេ?



ចម្លើយ៖

ចាប់តាំងពីពេលដែលមនុស្ស
បានធ្លាក់ក្នុងអំពើបាបមក គ្មាន
មនុស្សសាមញ្ញណាម្នាក់អាច
ប្រតិបត្តិតាមក្រឹត្យវិន័យរបស់
ព្រះបានយ៉ាងល្អឥតខ្ចោះឡើយ
ប៉ុន្តែផ្ទុយទៅវិញ មនុស្សយើង
តែងតែប្រព្រឹត្តល្មើសនៅក្នុង
ចិត្តគំនិត ពាក្យសម្តី និងការ
ប្រព្រឹត្ត។

**រ៉ូម ៣:១០-១២**

គ្មានអ្នកណាសុចរិតសោះ សូម្បីតែម្នាក់ក៏គ្មានផង
គ្មានអ្នកណាដែលយល់ គ្មានអ្នកណាដែលស្វែង
រកព្រះ គ្រប់គ្នាបានបែរចេញ ហើយត្រឡប់ជាឥត
ប្រយោជន៍ទាំងអស់គ្នា គ្មានអ្នកណាដែលប្រព្រឹត្ត
តាមសេចក្តីសប្បុរសសោះ តែម្នាក់ក៏គ្មានផង។

សំណួរទី១៤

# តើព្រះជាម្ចាស់បានបង្កើតយើងមកឲ្យគ្មានសមត្ថភាពក្នុងការប្រតិបត្តិតាមក្រឹត្យវិន័យរបស់ទ្រង់មែនឬ?

ចម្លើយ៖

ទេ! ប៉ុន្តែ អ្វីៗដែលទ្រង់បាន បង្កើតមកបានធ្លាក់ក្នុងអំពើ បាបដោយសារការមិនស្ដាប់ បង្គាប់របស់ឪពុកម្ដាយដើម ដំបូងរបស់យើងគឺលោក អ័ដាម និងនាង អេវ៉ា។ មនុស្ស យើងទាំងអស់គ្នាសុទ្ធតែ កើតមកនៅក្នុងអំពើបាប និង ពិរុទ្ធភាព មាននិស្ស័យពុក រលួយ ហើយមិនអាចប្រតិបត្តិ តាមក្រឹត្យវិន័យរបស់ព្រះបាន ឡើយ។

**រ៉ូម ៥:១២**

ដូច្នេះ ដែលបាបបានចូលមកក្នុងលោកីយ៍ ដោយសារមនុស្សតែម្នាក់ ហើយក៏មានសេចក្ដីស្លាប់ចូលមកដែរ ដោយសារអំពើបាបនោះជាយ៉ាងណា នោះសេចក្ដីស្លាប់បានឆ្លងរាលដាល ដល់មនុស្សគ្រប់គ្នាយ៉ាងនោះដែរ ដ្បិតគ្រប់គ្នាបានធ្វើបាបហើយ។

សំណួរទី១៥

# តើអ្វីទៅជាគោលបំណងរបស់ក្រឹត្យវិន័យ បើគ្មានអ្នកណាម្នាក់អាចប្រតិបត្តិតាមបានផង?



## ចម្លើយ៖

គោលបំណងរបស់ក្រឹត្យវិន័យគឺ ដើម្បីឲ្យយើងយល់ពីភាពបរិសុទ្ធ និងបំណងព្រះហឫទ័យរបស់ព្រះអង្គ ហើយនិងនិស្ស័យបាបរបស់យើងព្រមទាំងដួងចិត្តរបស់យើងដែលមិនស្តាប់បង្គាប់ទ្រង់។ ដូច្នេះ នេះហើយជាមូលហេតុដែលយើងត្រូវការព្រះសង្គ្រោះ។ ក្រឹត្យវិន័យក៏បង្រៀន និងដាស់តឿនឲ្យយើងឲ្យរស់នៅបែបសក្តិសមនឹងព្រះសង្គ្រោះរបស់យើងដែរ។

**រ៉ូម ៣:២០**

ដូច្នេះ គ្មានមនុស្សណាបានសុចរិតនៅចំពោះព្រះភ័ក្ត្រព្រះអង្គ ដោយការប្រព្រឹត្តតាមក្រឹត្យវិន័យទេ ព្រោះគម្ពីរវិន័យគ្រាន់តែនាំឲ្យគេស្គាល់អំពើបាបប៉ុណ្ណោះ (គខប)។

សំណួរទី១៦

# តើអ្វីទៅជាអំពើបាប?



ចម្លើយ៖

អំពើបាបគឺជាការបដិសេធ ឬ ក៏ការមិនទទួលស្គាល់ព្រះជាម្ចាស់នៅក្នុងពិភពលោកដែលទ្រង់បានបង្កើតមក គឺជាការបះបោរទាស់នឹងទ្រង់តាមរយៈការរស់នៅដោយមិនគោរពកោតខ្លាចដល់ទ្រង់ ការមិនមានលក្ខណសម្បត្តិ ឬការមិនប្រតិបត្តិតាមអ្វីដែលទ្រង់ទាមទារនៅក្នុងក្រឹត្យវិន័យរបស់ទ្រង់–ហើយសេចក្ដីស្លាប់ជាលទ្ធផលនៃអំពើបាប និងការបាក់បែកនៅក្នុងពិភពលោកទាំងអស់ដែលទ្រង់បានបង្កើតឡើង។

**១យ៉ូហាន ៣:៤**
ឯអស់អ្នកណាដែលប្រព្រឹត្តអំពើបាបវិញ នោះក៏ឈ្មោះថាប្រព្រឹត្តរំលងក្រឹត្យវិន័យដែរ ដ្បិតអំពើបាបជាការរំលងក្រឹត្យវិន័យហើយ។

សំណួរទី១៧

# តើអ្វីទៅជាការថ្វាយបង្គំរូបព្រះក្លែងក្លាយ?



## ចម្លើយ៖

ការថ្វាយបង្គំរូបព្រះក្លែងក្លាយគឺជាការជឿទុកចិត្តលើរបស់អ្វីមួយដែលព្រះជាម្ចាស់បានបង្កើតមក ជំនួសឲ្យព្រះដែលបង្កើតរបស់ទាំងនោះ ដើម្បីផ្ដល់ឲ្យយើងមានក្ដីសង្ឃឹម សុភមង្គល តម្លៃ និងសុវត្ថិភាព។

**រ៉ូម ១:២១, ២៥**

ព្រោះកាលគេបានស្គាល់ព្រះ នោះគេមិនបានតម្កើងទ្រង់ ទុកជាព្រះទេ ក៏មិនដឹងគុណទ្រង់ដែរ គេកើតមានគំនិតឥតប្រយោជន៍វិញ ហើយចិត្តគេ ដែលឥតយោបល់ ក៏បានត្រឡប់ជាងងឹតទៅ....គេបានផ្លាស់សេចក្ដីពិតនៃព្រះ ឲ្យទៅជាសេចក្ដីភូតភរវិញ ក៏កោតខ្លាច ហើយគោរពបូជាដល់របស់ដែលកើតមកជាជាងដល់ព្រះ ដែលបង្កើតរបស់ទាំងនោះមក ជាព្រះដែលមានព្រះពរអស់កល្បជានិច្ច។

សំណួរទី១៨

# តើព្រះជាម្ចាស់នឹងមិនដាក់ទោសចំពោះការមិនស្ដាប់បង្គាប់ និងការថ្វាយបង្គំរូបព្រះក្លែងក្លាយរបស់យើងទេឬអី?



ចម្លើយ៖

ទេ! គ្រប់អំពើបាបទាំងអស់ទាស់ប្រឆាំងនឹងអធិបតេយ្យភាព ភាពបរិសុទ្ធ និងសេចក្តីសប្បុរសរបស់ព្រះអង្គ ហើយក៏ប្រឆាំងនឹងក្រឹត្យវិន័យដ៏សុចរិតរបស់ទ្រង់ដែរ។ ព្រះជាម្ចាស់ក៏មានសេចក្តីក្រោធដ៏សុចរិតទាស់នឹងអំពើបាបរបស់យើង ហើយទ្រង់ប្រាកដជានឹងដាក់ទោសយ៉ាងយុត្តិធម៌ចំពោះអំពើបាបទាំងនោះក្នុងជីវិតនេះ និងក្នុងជីវិតខាងមុខផងដែរ។

**អេភេសូរ ៥:៥-៦**

ចូរអ្នករាល់គ្នាដឹងសេចក្តីនេះឲ្យច្បាស់ថា អ្នកប្រព្រឹត្តអំពើសហាយស្មន់ មនុស្សស្មោកគ្រោក ឬមនុស្សដែលមានចិត្តលោភលន់ (គឺមនុស្សថ្វាយបង្គំរូបព្រះ) មិនអាចគ្រងមរតកក្នុងព្រះរាជ្យរបស់ព្រះគ្រីស្ទ និងរបស់ព្រះបានឡើយ។ កុំឲ្យអ្នកណាម្នាក់បញ្ឆោតអ្នករាល់គ្នា ដោយពាក្យសម្តីឥតប្រយោជន៍ឡើយ ដ្បិតគឺដោយព្រោះសេចក្តីទាំងនេះហើយ ដែលសេចក្តីក្រោធរបស់ព្រះធ្លាក់មកលើអស់អ្នកដែលមិនស្តាប់បង្គាប់ (គកស)។

សំណួរទី១៩

# តើមានមធ្យោបាយណាមួយដែលអាចនាំឲ្យយើងគេចផុតពីការដាក់ទោសរបស់ព្រះ ហើយនាំឲ្យយើងជានាជាមួយព្រះអង្គវិញបានទេ?



ចម្លើយ៖

មាន! ដើម្បីបំពេញតាមភាពយុត្តិធម៌របស់ទ្រង់ ព្រះជាម្ចាស់ផ្ទាល់–ដោយកើតចេញពីព្រះហឫទ័យមេត្តាករុណាតែប៉ុណ្ណោះ–បានផ្សះផ្សាយើងជាមួយនឹងទ្រង់ ហើយបានរំដោះយើងពីអំពើបាប និងចេញពីការដាក់ទោសចំពោះអំពើបាបតាមរយៈព្រះដ៏ប្រោសលោះ។

**អេសាយ ៥៣:១០-១១**

ទោះបើយ៉ាងនោះ គង់តែព្រះយេហូវ៉ាបានសព្វព្រះហឫទ័យនឹងវាយទ្រង់ឲ្យជាំ ហើយឲ្យឈឺចាប់ កាលណាព្រះជន្មទ្រង់បានត្រូវថ្វាយទុក្ខជាយញ្ញបូជាលោះបាបហើយ នោះទ្រង់នឹងបានឃើញពូជពង្សរបស់ទ្រង់ ហើយនិងចម្រើនព្រះជន្មទ្រង់ឲ្យយឺនយូរតទៅ ឯបំណងព្រះហឫទ័យនៃព្រះយេហូវ៉ា នោះនឹងចឿនឡើងដោយព្រះហស្តទ្រង់ ទ្រង់នឹងឃើញផលនៃការដែលព្រលឹងទ្រង់រងវេទនា នោះនឹងបានស្កប់ស្កល់ផង អ្នកដ៏សុចរិត គឺជាអ្នកបម្រើរបស់អញទ្រង់នឹងធ្វើឲ្យមនុស្សជាច្រើនបានសុចរិត ដោយគេស្គាល់ដល់ទ្រង់ ហើយទ្រង់នឹងទទួលរងទោសចំពោះអំពើទុច្ចរិតរបស់គេ។

សំណួរទី២០

# តើអ្នកណាទៅជាព្រះដ៏ប្រោសលោះនោះ?



ចម្លើយ៖

ព្រះអម្ចាស់យេស៊ូវគ្រីស្ទគឺជាព្រះដ៏ប្រោសលោះតែមួយអង្គគត់ ដែលជាព្រះរាជបុត្រាដ៏មានព្រះជន្មអស់កល្បជានិច្ចរបស់ព្រះ ហើយក្នុងទ្រង់ ព្រះបានយកនិស្ស័យជាមនុស្ស ហើយទទួលយកនូវទណ្ឌកម្មនៃអំពើបាបដាក់នៅលើអង្គទ្រង់ផ្ទាល់ដែរ។

**១ធីម៉ូថេ ២:៥**

ពីព្រោះមានព្រះតែ១ ហើយមានអ្នកសង្គ្របសង្គ្រមតែ១ នៅកណ្តាលព្រះ និងមនុស្ស គឺជាមនុស្សដ៏ជាព្រះគ្រីស្ទយេស៊ូវនោះ។

ផ្នែកទី២

# ព្រះគ្រីស្ទ ការប្រោសលោះ និងព្រះគុណ

សំណួរទី២១

# តើយើងត្រូវការព្រះដ៏ប្រោសលោះដែលមានលក្ខណៈយ៉ាងដូចម្តេច ដើម្បីនាំយើងទៅកាន់ព្រះជាម្ចាស់វិញ?



## ចម្លើយ៖

យើងត្រូវការព្រះដ៏ប្រោសលោះ ដែលជាមនុស្ស ១០០% និងជាព្រះ ១០០%។

**អេសាយ ៩:៦**

ដ្បិតមានព្រះរាជបុត្រមួយអង្គប្រសូតមក សម្រាប់យើង ព្រះជាម្ចាស់បានប្រទានព្រះបុត្រាមួយព្រះអង្គមកយើងហើយ។ បុត្រនោះទទួលអំណាចគ្រប់គ្រង គេនឹងថ្វាយព្រះនាមថា៖ «ព្រះដ៏គួរស្ងើចសរសើរ ព្រះប្រកបដោយព្រះប្រាជ្ញាញាណ ព្រះដ៏មានឫទ្ធិចេស្ដា ព្រះបិតាដ៏មានព្រះជន្មគង់នៅអស់កល្បជានិច្ច ព្រះអង្គម្ចាស់នៃសេចក្ដីសុខសាន្ត» (គខប)។

សំណួរទី២២

# ហេតុអ្វីបានជាព្រះដ៏ប្រោសលោះត្រូវតែជាមនុស្ស ១០០%?



ចម្លើយ៖

ដោយសារក្នុងនិស្ស័យជាមនុស្ស ទ្រង់អាចស្ដាប់បង្គាប់ក្រឹត្យវិន័យទាំងអស់បានយ៉ាងល្អឥតខ្ចោះ និងទទួលរងនូវទណ្ឌកម្មនៃអំពើបាបរបស់មនុស្សជំនួសយើង។ ដោយសារព្រះអង្គបានធ្វើយ៉ាងដូច្នោះ ទ្រង់អាចអាណិតអាសូរដល់ភាពទន់ខ្សោយរបស់យើងផងដែរ។

**ហេព្រើរ ២:១៧**

ហេតុនេះហើយបានជាគួរឲ្យព្រះអង្គ មានលក្ខណៈដូចបងប្អូនរបស់ព្រះអង្គគ្រប់ជំពូកដែរ ដើម្បីធ្វើជាសម្ដេចសង្ឃ ដែលមានព្រះហឫទ័យមេត្ដាករុណា ហើយក៏ស្មោះត្រង់ក្នុងការបម្រើព្រះ ដើម្បីថ្វាយយញ្ញបូជាសម្រាប់រំដោះប្រជាជនឲ្យរួចពីបាប (គកស)។

សំណួរទី២៣

# ហេតុអ្វីបានជាព្រះដ៏ប្រោស លោះត្រូវតែជាព្រះ ១០០%?



ចម្លើយ៖

ពីព្រោះតាមរយៈការមាននិស្ស័យជាព្រះ នោះការស្តាប់បង្គាប់ និងការរងទុក្ខរបស់ទ្រង់នឹងមានភាពល្អឥតខ្ចោះ ហើយមានប្រសិទ្ធិភាព។ មិនតែប៉ុណ្ណោះ ព្រះអង្គអាចទ្រាំទ្រនឹងសេចក្តីក្រោធដ៏សុចរិតរបស់ព្រះវរបិតា ដែលទាស់នឹងអំពើបាប ប៉ុន្តែទ្រង់នៅតែអាចយកឈ្នះលើសេចក្តីស្លាប់បានផងដែរ។

**កិច្ចការ ២:២៤**
ប៉ុន្តែ ព្រះបានប្រោសទ្រង់ឲ្យមានព្រះជន្មរស់ឡើងវិញ ដោយបានស្រាយចំណងនៃសេចក្តីស្លាប់ចេញ ពីព្រោះសេចក្តីស្លាប់ គ្មានអំណាចនឹងឃុំឃាំងទ្រង់ទុកបានឡើយ។

សំណួរទី២៤

# ហេតុអ្វីបានជាព្រះគ្រីស្ទដែលជាព្រះដ៏ប្រោសលោះចាំបាច់ត្រូវសុគត?



ចម្លើយ៖

ដោយសារសេចក្ដីស្លាប់គឺជាទណ្ឌកម្មនៃអំពើបាប ដូច្នេះព្រះគ្រីស្ទបានសុគ្រព្រះទ័យសុគតជំនួសយើង ដើម្បីរំដោះយើងចេញពីអំណាច និងការដាក់ទោសនៃអំពើបាប ហើយនាំយើងទៅឯព្រះជាម្ចាស់វិញ។ តាមរយៈការសុគតរបស់ទ្រង់ដែលធួននឹងបាបជំនួសយើង នោះមានតែព្រះអង្គតែមួយប៉ុណ្ណោះទេ ដែលអាចរំដោះយើងឲ្យរួចពីស្ថាននរក ហើយទទួលបាននូវការអត់ទោសបាប សេចក្ដីសុចរិត និងជីវិតអស់កល្បជានិច្ចសម្រាប់យើង។

**កូឡូស ១:២១-២២**

រីឯអ្នករាល់គ្នា ដែលពីដើមត្រូវឃ្លាតឆ្ងាយ ហើយជាខ្មាំងសត្រូវក្នុងគំនិត ដោយសារអំពើអាក្រក់ ឥឡូវនេះ ព្រះអង្គបានផ្សះផ្សាក្នុងរូបសាច់ព្រះអង្គ ដោយបានទទួលសុគត ដើម្បីថ្វាយអ្នករាល់គ្នាជាតង្វាយបរិសុទ្ធ ឥតសៅហ្មង ហើយឥតកន្លែងបន្ទោសបាននៅចំពោះព្រះអង្គ (គកស)។

# តើការសុគតរបស់ព្រះគ្រីស្ទ មានន័យថា យើងអាចទទួលបានការអត់ទោសចំពោះអំពើបាបទាំងអស់របស់យើងមែនឬ?



## ចម្លើយ៖

មែន! ពីព្រោះការសុគតរបស់
ព្រះគ្រីស្ទនៅលើឈើឆ្កាង
បានបង់ថ្លៃសងទាំងស្រុង
សម្រាប់ទណ្ឌកម្មនៃអំពើបាប
របស់យើង។ ដោយព្រោះព្រះ
គុណ ព្រះវរបិតាបានរាប់យើង
ជាសុចរិតដោយសារសេចក្ដី
សុចរិតរបស់ព្រះគ្រីស្ទហាក់ដូច
ជាសេចក្ដីសុចរិតនោះជាសេចក្ដី
សុចរិតរបស់យើងផ្ទាល់ ហើយ
ព្រះអង្គក៏លែងនឹកចាំអំពីអំពើ
បាបរបស់យើងទៀតផងដែរ។

**២កូរិនថូស ៥:២១**
ដ្បិតព្រះគ្រីស្ទដែលមិនបានស្គាល់បាបសោះ តែព្រះ
បានធ្វើឲ្យព្រះអង្គត្រឡប់ជាតួបាបជំនួសយើង ដើម្បី
ឲ្យយើងបានត្រឡប់ជាសេចក្ដីសុចរិតរបស់ព្រះ នៅ
ក្នុងព្រះអង្គ (គកស)។

សំណួរទី២៦

# តើការសុគតរបស់ព្រះគ្រីស្ទបានប្រោសលោះអ្វីផ្សេងទៀត?

ចម្លើយ៖

ការសុគតរបស់ព្រះគ្រីស្ទគឺជាដើមចមនៃការប្រោសលោះ និងការស្តារឡើងវិញនូវអ្វីៗទាំងអស់ដែលព្រះជាម្ចាស់បានបង្កើតមកដែលបានធ្លាក់ក្នុងអំពើបាប ខណៈពេលដែលព្រះអង្គគ្រប់គ្រងលើអ្វីៗទាំងអស់ប្រកបដោយព្រះចេស្តាសម្រាប់ជាសិរីល្អរបស់ទ្រង់ផ្ទាល់ និងសម្រាប់ជាប្រយោជន៍ដល់អ្វីៗដែលទ្រង់បានបង្កើតមក។

**កូឡុស ១:១៩-២០**

ដ្បិតព្រះបានសព្វព្រះហឫទ័យ ឲ្យគ្រប់ទាំងសេចក្ដីពោរពេញបានស្ថិតនៅក្នុងទ្រង់ ហើយឲ្យបានផ្សះផ្សាគ្រប់ទាំងអស់ ឲ្យជានឹងអង្គទ្រង់ ដោយសារព្រះរាជបុត្រានោះ ទោះបើរបស់នៅស្ថានសួគ៌ ឬនៅផែនដីក្តី ទាំងតាំងស្ពានមេត្រី ដោយសារព្រះលោហិតនៃឈើឆ្កាងទ្រង់។

# តើមនុស្សទាំងអស់ក៏នឹងបានសេចក្ដីសង្គ្រោះតាមរយៈព្រះគ្រីស្ទ ដូចដែលមនុស្សទាំងអស់បានបាត់បង់តាមរយៈលោក អ័ដាម ដែរមែនឬ?



ចម្លើយ៖

មិនមែនទេ! មានតែអស់អ្នកណាដែលព្រះជាម្ចាស់បានជ្រើសរើស ហើយបានរួបរួមជាមួយព្រះគ្រីស្ទតាមរយៈជំនឿតែប៉ុណ្ណោះ។ ទោះជាយ៉ាងណាក៏ដោយ ក៏សេចក្ដីមេត្តាករុណារបស់ព្រះអង្គទ្រង់បានសម្ដែងព្រះគុណសាមញ្ញដល់មនុស្សទាំងអស់ សូម្បីតែអស់អ្នកដែលទ្រង់មិនបានជ្រើសរើសក្ដី ក៏តាមរយៈការរារាំងនូវផលលំបាកនៃអំពើបាប ហើយអនុញ្ញាតឲ្យមនុស្សមានសមត្ថភាពបង្កើតសង្គមដែលចេះជួយគ្នាទៅវិញទៅមកបាន។

**រ៉ូម ៥:១៧**

ដ្បិតបើសិនជាសេចក្ដីស្លាប់បានសោយរាជ្យ ដោយសារមនុស្សតែម្នាក់ ដោយព្រោះម្នាក់នោះឯងបានប្រព្រឹត្តសេចក្ដីរំលង ដូច្នេះ ប្រាកដជាពួកអ្នកដែលទទួលព្រះគុណដ៏បរិបូរ និងអំណោយទានជាសេចក្ដីសុចរិត នោះនឹងបានសោយរាជ្យក្នុងជីវិតលើសទៅទៀត ដោយសារតែម្នាក់ដែរ គឺជាព្រះយេស៊ូវគ្រីស្ទ។

សំណួរទី២៨

# ក្រោយពីស្លាប់ទៅ តើនឹងមានអ្វីកើតឡើងចំពោះអស់អ្នកដែលមិនបានរួបរួមជាមួយនឹងព្រះគ្រីស្ទតាមរយៈជំនឿ?



ចម្លើយ៖

នៅថ្ងៃជំនុំជម្រះ ពួកគេនឹងទទួលនូវការវិនិច្ឆ័យទោសពីព្រះជាម្ចាស់ដ៏គួរឲ្យស្ញែងខ្លាច ប៉ុន្តែជាការវិនិច្ឆ័យទោសដ៏យុត្តិធម៌។ ពួកគេនឹងត្រូវបានបណ្តេញចេញពីព្រះវត្តមានរបស់ព្រះអង្គដែលប្រកបដោយគុណប្រយោជន៍ឲ្យទៅឯស្ថាននរកដ៏អស់កល្បជានិច្ច ដើម្បីរងទុក្ខវេទនាយ៉ាងធ្ងន់ធ្ងរស្របតាមភាពយុត្តិធម៌។

**យ៉ូហាន ៣:១៦-១៨, ៣៦**

ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម៉្លេះ បានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ ពីព្រោះព្រះទ្រង់មិនបានចាត់ព្រះរាជបុត្រាទ្រង់ ឲ្យមកក្នុងលោកីយ៍ ដើម្បីនឹងជំនុំជម្រះលោកីយ៍នោះទេ គឺឲ្យលោកីយ៍បានសង្គ្រោះ ដោយសារទ្រង់វិញ ឯអ្នកណាដែលជឿដល់ទ្រង់ នោះមិនជាប់មានទោសទេ តែអ្នកណាដែលមិនជឿវិញ នោះត្រូវមានទោសហើយ ពីព្រោះមិនបានជឿដល់ព្រះនាមនៃព្រះរាជបុត្រាតែ១របស់ព្រះ....ឯអ្នកណាដែលជឿដល់ព្រះរាជបុត្រា នោះមានជីវិតដ៏នៅអស់កល្បជានិច្ចហើយ តែអ្នកណាដែលមិនព្រមជឿដល់ព្រះរាជបុត្រាវិញ នោះនឹងមិនឃើញជីវិតសោះឡើយ គឺសេចក្តីក្រោធរបស់ព្រះ តែងនៅជាប់លើអ្នកនោះឯង។

សំណួរទី២៩

# តើយើងអាចទទួលបានសេចក្ដីសង្គ្រោះយ៉ាងដូចម្ដេច?

ចម្លើយ៖

យើងអាចទទួលបានសេចក្ដីសង្គ្រោះតែតាមរយៈជំនឿលើព្រះយេស៊ូវគ្រីស្ទ និងលើការសុគតឲ្យធួននឹងបាបរបស់ទ្រង់ជំនួសយើងនៅលើឈើឆ្កាងតែប៉ុណ្ណោះ។ ទោះបើយើងជាប់មានពិរុទ្ធភាពដោយព្រោះមិនស្ដាប់បង្គាប់ព្រះ និងទោរទន់ទៅរកការអាក្រក់ទាំងអស់ក៏ដោយ ក៏ព្រះនៅតែរាប់យើងថាជាសុចរិតដោយព្រោះសេចក្ដីសុចរិតដ៏គ្រប់លក្ខណ៍របស់ព្រះគ្រីស្ទ នៅពេលដែលយើងកែប្រែចិត្ត និងជឿលើទ្រង់។ ការទាំងអស់នេះមានប្រភពមកពីព្រះគុណទ្រង់តែប៉ុណ្ណោះ មិនមែនមកពីអំពើល្អរបស់យើងនោះទេ។

**អេភេសូរ ២:៨-៩**

ដ្បិតគឺដោយព្រះគុណ ដែលអ្នករាល់គ្នាបានសង្គ្រោះដោយសារសេចក្ដីជំនឿ ហើយសេចក្ដីនោះក៏មិនមែនកើតពីអ្នករាល់គ្នាដែរ គឺជាអំណោយទានរបស់ព្រះវិញ ក៏មិនមែនដោយការប្រព្រឹត្តដែរ ក្រែងអ្នកណាអួតខ្លួន។

សំណួរទី៣០

# តើអ្វីទៅជាជំនឿលើព្រះយេស៊ូវគ្រីស្ទ?



ចម្លើយ៖

ជំនឿលើព្រះយេស៊ូវគ្រីស្ទគឺជាការទទួលស្គាល់សេចក្ដីពិតគ្រប់យ៉ាង ដែលព្រះបានបើកសម្ដែង នៅក្នុងព្រះបន្ទូលទ្រង់ ហើយក៏ជាការជឿទុកចិត្តលើទ្រង់ និងជាការទទួលយកទ្រង់ព្រមទាំងការពឹងអាងលើទ្រង់តែមួយអង្គគត់សម្រាប់សេចក្ដីសង្គ្រោះដែលទ្រង់បានប្រទានដល់យើងនៅក្នុងដំណឹងល្អផងដែរ។

**កាឡាទី ២:២០**

ខ្ញុំបានជាប់ឆ្កាងជាមួយនឹងព្រះគ្រីស្ទ ប៉ុន្តែ ខ្ញុំរស់នៅ មិនមែនជាខ្ញុំទៀត គឺជាព្រះគ្រីស្ទទ្រង់រស់ក្នុងខ្ញុំវិញ ហើយដែលខ្ញុំរស់ក្នុងសាច់ឈាមឥឡូវនេះ នោះគឺរស់ដោយសេចក្ដីជំនឿ ជឿដល់ព្រះរាជបុត្រានៃព្រះ ដែលទ្រង់ស្រឡាញ់ខ្ញុំ ក៏បានប្រគល់ព្រះអង្គទ្រង់ជំនួសខ្ញុំហើយ។

សំណួរទី៣១

# នៅក្នុងជំនឿដ៏ពិតតើយើងជឿលើអ្វីខ្លះ?



ចម្លើយ៖

យើងជឿលើគ្រប់ចំណុចដែលដំណឹងល្អបានបង្រៀនដល់យើង។ គោលជំនឿរបស់ពួកសាវ័ករៀបរាប់នូវអ្វីដែលយើងជឿដូចតទៅ៖ យើងខ្ញុំជឿលើព្រះវរបិតា ដែលមានឥទ្ធិឫទ្ធិចេស្ដាដ៏លើសលប់ ជាព្រះដែលបានបង្កើតផ្ទៃមេឃ និងផែនដី។ ហើយយើងខ្ញុំជឿលើព្រះយេស៊ូវគ្រីស្ទ ដែលជាព្រះរាជបុត្រាតែមួយអង្គគត់របស់ព្រះជាម្ចាស់ ព្រះអង្គជាព្រះអម្ចាស់នៃយើង។ ព្រះអង្គបានចាប់បដិសន្ធិតាមរយៈព្រះវិញ្ញាណបរិសុទ្ធ។ ព្រះអង្គបានប្រសូតពីនាង ម៉ារា ដែលជាស្ត្រីក្រមុំព្រហ្មចារី។ ព្រះអង្គបានរងទុក្ខក្រោមអំណាចគ្រប់គ្រងរបស់លោកប៉ុនទាស-ពីឡាត់ ត្រូវបានគេឆ្កាងបានសុគត ហើយត្រូវបានគេបញ្ចុះក្នុងផ្នូរ។ ព្រះអង្គបានយាងចុះទៅឯស្ថាននរក[១]។ នៅថ្ងៃទីបី ព្រះអង្គមានព្រះជន្មរស់ឡើងវិញ។ ព្រះអង្គបានយាងឡើងទៅឯស្ថានសួគ៌ ហើយទ្រង់កំពុងគង់នៅខាងស្ដាំព្រះហស្តព្រះវរបិតាដែលមានឥទ្ធិឫទ្ធិចេស្ដាដ៏លើសលប់ ហើយព្រះអង្គនឹងយាងត្រឡប់មកពីស្ថានសួគ៌វិញ ដើម្បីកាត់ទោសអស់ទាំងមនុស្សរស់ និងមនុស្សស្លាប់។

យើងខ្ញុំជឿលើព្រះវិញ្ញាណបរិសុទ្ធ លើក្រុមជំនុំសកលដ៏បរិសុទ្ធ លើការប្រកបគ្នានៃពួកបរិសុទ្ធ លើការអត់ទោសបាប លើការរស់ឡើងវិញនៃរូបកាយ និងលើជីវិតដ៏នៅអស់កល្បជានិច្ច។ អាម៉ែន។

១. ឬក៏ស្ថានឃុំមនុស្សស្លាប់។

**យូដាស ៣**

ពួកស្ងួនភ្ងាអើយ កាលខ្ញុំកំពុងមានបំណងចង់សរសេរមកអ្នករាល់គ្នា អំពីការសង្គ្រោះ ដែលយើងបានទទួលរួមគ្នា ខ្ញុំយល់ថា ខ្ញុំត្រូវតែសរសេរមកដាស់តឿនអ្នករាល់គ្នាឲ្យខំតយុទ្ធដើម្បីជំនឿ ដែលព្រះបានប្រគល់មកពួកបរិសុទ្ធ ម្ដងជាសម្រេច។

សំណួរទី៣២

# តើការរាប់ជាសុចរិត និងការញែកជាបរិសុទ្ធមានន័យយ៉ាងដូចម្តេច?



ចម្លើយ៖

ការរាប់ជាសុចរិតមានន័យថា ព្រះជាម្ចាស់បានប្រកាសថាយើងជាមនុស្សសុចរិតនៅចំពោះទ្រង់ ដែលការនេះអាចកើតឡើងបានដោយសារការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រីស្ទសម្រាប់យើង។ ការញែកជាបរិសុទ្ធមានន័យថា ការរីកចម្រើនបន្តិចម្តងៗខាងឯសេចក្តីសុចរិត ដែលការនេះអាចកើតឡើងបានតាមរយៈព្រះរាជកិច្ចនៃព្រះវិញ្ញាណបរិសុទ្ធក្នុងយើង។

**១ពេត្រុស ១:១-២**

សូមជម្រាបមកបងប្អូន ដែលបែកខ្ញែកគ្នា....ជាអ្នកដែលព្រះ ជាព្រះវរបិតាបានជ្រើសរើស និងបានបម្រុងទុក ហើយព្រះវិញ្ញាណបានញែកជាបរិសុទ្ធ ដើម្បីឲ្យបានស្តាប់បង្គាប់ព្រះយេស៊ូវគ្រីស្ទ ព្រមទាំងបានព្រះលោហិតរបស់ព្រះអង្គប្រោះលើខ្លួន។ សូមឲ្យអ្នករាល់គ្នាបានប្រកបដោយព្រះគុណ និងសេចក្តីសុខសាន្ត កាន់តែច្រើនឡើង (គកស)។

សំណួរទី៣៣

# តើគួរឲ្យអស់អ្នកដែលមាន ជំនឿលើព្រះគ្រីស្ទរួចហើយ ស្វែងរកសេចក្ដីសង្គ្រោះដោយ ពឹងលើការប្រព្រឹត្តរបស់ខ្លួនឯង ឬពីកន្លែងណាផ្សេងទៀត?

## ចម្លើយ៖

ទេ! ពួកគេមិនគួរធ្វើដូច្នោះឡើយ ដ្បិតនៅក្នុងព្រះគ្រីស្ទមានអ្វីៗគ្រប់យ៉ាងដែលចាំបាច់សម្រាប់សេចក្ដីសង្គ្រោះ។ ការស្វែងរកសេចក្ដីសង្គ្រោះដោយពឹងលើការប្រព្រឹត្តអំពើល្អគឺជាការបដិសេធថា ព្រះគ្រីស្ទជាព្រះដ៏ប្រោសលោះ និងជាព្រះសង្គ្រោះតែមួយអង្គគត់ទេ។

**កាឡាទី ២:១៦**

យើងដឹងថា មនុស្សមិនបានរាប់ជាសុចរិត ដោយប្រព្រឹត្តតាមក្រឹត្យវិន័យនោះឡើយ គឺដោយសេចក្ដីជំនឿ ជឿដល់ព្រះយេស៊ូវគ្រីស្ទវិញ ហេតុនោះបានជាយើងជឿដល់ព្រះគ្រីស្ទយេស៊ូវ ដើម្បីឲ្យបានរាប់ជាសុចរិត ដោយសារសេចក្ដីជំនឿ ជឿដល់ព្រះគ្រីស្ទនោះ មិនមែនដោយប្រព្រឹត្តតាមក្រឹត្យវិន័យទេ ពីព្រោះគ្មានមនុស្សណាបានរាប់ជាសុចរិតដោយប្រព្រឹត្តតាមក្រឹត្យវិន័យឡើយ។

សំណួរទី៣៨

# ដោយសារព្រះបានប្រោសលោះយើងដោយព្រះគុណតាមរយៈព្រះគ្រីស្ទតែមួយគត់ តើយើងនៅតែត្រូវប្រព្រឹត្តអំពើល្អ និងស្ដាប់បង្គាប់តាមព្រះបន្ទូលព្រះដែរឬទេ?

ចម្លើយ៖

ត្រូវហើយ! ពីព្រោះព្រះគ្រីស្ទ បានប្រោសលោះយើងដោយ ព្រះលោហិតរបស់ទ្រង់ ព្រះអង្គ ក៏បានស្តារយើងឡើងវិញដោយ ព្រះវិញ្ញាណទ្រង់ដែរ ដើម្បីឲ្យ ជីវិតរបស់យើងអាចបង្ហាញពី ក្តីស្រឡាញ់ និងការដឹងគុណ ចំពោះទ្រង់។ និងដើម្បីឲ្យផល ផ្លែទាំងនោះបញ្ជាក់ឲ្យដឹងច្បាស់ ថា យើងបានសង្គ្រោះតាមរយៈ ជំនឿ ហើយនិងដើម្បីនាំអ្នក ដទៃឲ្យជឿលើព្រះគ្រីស្ទដែរ តាមរយៈការប្រព្រឹត្តដោយចេះ កោតខ្លាចព្រះជាម្ចាស់របស់ យើង។

**១ពេត្រុស ២:៩-១២**

តែអ្នករាល់គ្នាជាពូជជ្រើសរើស ជាពួកសង្ឃហ្លួង ជាសាសន៍បរិសុទ្ធ ជារាស្ត្រដ៏ជាកេរ្តិ៍អាករនៃព្រះ ដើម្បីឲ្យអ្នករាល់គ្នាបានសម្តែងចេញ ឲ្យឃើញអស់ទាំងលក្ខណៈរបស់ព្រះ ដែលទ្រង់បានហៅអ្នករាល់គ្នាចេញពីសេចក្តីងងឹត មកក្នុងពន្លឺអស្ចារ្យរបស់ទ្រង់ ពីដើម អ្នករាល់គ្នាមិនមែនជាសាសន៍ណាមួយទេ តែឥឡូវនេះជាសាសន៍របស់ព្រះវិញ ពីដើមមិនបានទទួលសេចក្តីមេត្តាករុណាទេ តែឥឡូវនេះបានទទួលហើយ។ ឱពួកស្ងួនភ្ងាអើយ ខ្ញុំទូន្មានអ្នករាល់គ្នាទុកដូចជាពួកប្រទេសក្រៅ ហើយដូចជាពួកអ្នកដែលគ្រាន់តែសំណាក់នៅថា ចូរឲ្យអ្នករាល់គ្នាចៀសពីសេចក្តីប៉ងប្រាថ្នាខាងសាច់ឈាម ដែលតយុទ្ធនឹងព្រលឹងវិញ្ញាណចេញ ទាំងប្រព្រឹត្តដោយទៀងត្រង់ នៅក្នុងពួកសាសន៍ដទៃ ដើម្បីនៅកន្លែងណាដែលគេនិយាយដើម ពីអ្នករាល់គ្នា ទុកដូចជាមនុស្សប្រព្រឹត្តអាក្រក់ នោះឲ្យគេបានសរសើរដល់ព្រះ នៅថ្ងៃដែលទ្រង់យាងមកប្រោស ដោយគេឃើញការល្អរបស់អ្នករាល់គ្នាវិញ។

សំណួរទី៣៩

# ដោយសារព្រះបានប្រោសលោះយើងដោយព្រះគុណតែប៉ុណ្ណោះតាមរយៈជំនឿតែមួយគត់ តើជំនឿនេះកើតមកពីណា?



ចម្លើយ៖

អំណោយទានទាំងអស់ដែលយើងទទួលបានមកពីព្រះគ្រីស្ទ គឺយើងទទួលបានតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ដែលនេះមានរួមទាំងជំនឿផងដែរ។

**ទីតុស ៣:៤-៦**

ប៉ុន្តែ កាលសេចក្តីសប្បុរស និងសេចក្តីស្រឡាញ់របស់ព្រះ ជាព្រះសង្គ្រោះនៃយើងបានលេចមក ព្រះអង្គក៏បានសង្គ្រោះយើង មិនមែនដោយអំពើដែលយើងបានប្រព្រឹត្តសុចរិតនោះទេ គឺដោយព្រះហឫទ័យមេត្តាករុណារបស់ព្រះអង្គវិញ ដោយសារការលាងសម្អាតឲ្យបានកើតជាថ្មី និងការធ្វើឲ្យមានជីវិតជាថ្មីដោយសារព្រះវិញ្ញាណបរិសុទ្ធ។ ព្រះអង្គបានចាក់បង្ហូរមកលើយើងជាបរិបូរ ដោយសារព្រះយេស៊ូវគ្រីស្ទ ជាព្រះសង្គ្រោះនៃយើង (គកស)។

ផ្នែកទី៣

# ព្រះវិញ្ញាណ ការស្ដារឡើងវិញ និងការរីកចម្រើនក្នុងព្រះគុណ

សំណួរទី៣៦

# តើយើងជឿអ្វីខ្លះអំពីព្រះវិញ្ញាណបរិសុទ្ធ?



## ចម្លើយ៖

យើងជឿថាព្រះវិញ្ញាណបរិសុទ្ធ
គឺជាព្រះដែលគង់នៅជាមួយ
នឹងព្រះវរបិតា និងព្រះរាជបុត្រា
តាំងពីអស់កល្បជានិច្ចមក។
ហើយថា ព្រះជាម្ចាស់ប្រទាន
ទ្រង់ដល់អស់អ្នកណាដែល
ជឿព្រះជាម្ចាស់នឹងមិនដកព្រះ
វិញ្ញាណបរិសុទ្ធចេញពីពួកគេ
ជាដាច់ខាត។

**យ៉ូហាន ១៤:១៦-១៧**

ខ្ញុំនឹងទូលសូមដល់ព្រះវរបិតា ហើយព្រះអង្គនឹង ប្រទានព្រះជាជំនួយមួយអង្គទៀត មកអ្នករាល់គ្នា ឲ្យ បានគង់នៅជាមួយជារៀងរហូត គឺជាព្រះវិញ្ញាណនៃ សេចក្ដីពិត ដែលលោកីយ៍ទទួលមិនបាន ព្រោះមិន ឃើញ ក៏មិនស្គាល់ព្រះអង្គផង តែអ្នករាល់គ្នាស្គាល់ ដ្បិតព្រះអង្គគង់ជាមួយ ហើយសណ្ឋិតនៅក្នុងអ្នក រាល់គ្នា (គកស)។

សំណួរទី៣៧

# តើព្រះវិញ្ញាណបរិសុទ្ធជួយយើងដោយរបៀបណាខ្លះ?



## ចម្លើយ៖

ព្រះវិញ្ញាណបរិសុទ្ធជួយយើងឲ្យទទួលស្គាល់អំពើបាបរបស់ខ្លួនឯង ទ្រង់កម្សាន្តចិត្តយើង ដឹកនាំយើង ប្រទាននូវអំណោយទានខាងឯវិញ្ញាណ និងបំណងចិត្តដល់យើងក្នុងការស្តាប់បង្គាប់ព្រះជាម្ចាស់ ហើយព្រះអង្គជួយយើងក្នុងការអធិស្ឋាន និងឲ្យយល់ព្រះបន្ទូលព្រះជាម្ចាស់។

**អេភេសូរ ៦:១៧-១៨**

ចូរយកសេចក្តីសង្គ្រោះទុកជាមួកសឹក និងដាវរបស់ព្រះវិញ្ញាណដែរ គឺជាព្រះបន្ទូល ព្រមទាំងប្រើសេចក្តីអធិស្ឋាន និងសេចក្តីទូលអង្វរគ្រប់យ៉ាង ដើម្បីអធិស្ឋានដោយព្រះវិញ្ញាណរាល់ពេលរាល់វេលា ហើយចាំយាមក្នុងសេចក្តីនោះឯង ដោយនូវគ្រប់ទាំងសេចក្តីខ្ជាប់ខ្ជួន និងសេចក្តីទូលអង្វរឲ្យពួកបរិសុទ្ធទាំងអស់។

សំណួរទី៣៨

# តើអ្វីទៅជាការអធិស្ឋាន?



ចម្លើយ៖

ការអធិស្ឋានគឺជាការរៀបរាប់នូវអ្វីៗដែលមាននៅក្នុងដួងចិត្តរបស់យើងទៅកាន់ព្រះជាម្ចាស់តាមរយៈការសរសើរតម្កើង ការទូលអង្វរ ការលន់តួបាប និង ការអរព្រះគុណ។

**ទំនុកតម្កើង ៦២:៨**

ជនទាំងឡាយអើយ ចូរទុកចិត្តនឹងទ្រង់ជានិច្ច ចូរអ្នករាល់គ្នាប្លុងចិត្តនៅចំពោះទ្រង់ ព្រះទ្រង់ជាទីពឹងជ្រកសម្រាប់យើងខ្ញុំ។

សំណួរទី៣៩

# តើយើងគួរអធិស្ឋានដោយមានអាកប្បកិរិយាបែបណាទៅ?



ចម្លើយ៖

យើងគួរអធិស្ឋានដោយមានសេចក្តីស្រឡាញ់ ការតស៊ូទ្រាំទ្រ និងការអរព្រះគុណដោយបន្ទាបខ្លួនចុះចូលចំពោះបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ទាំងដឹងថា ទ្រង់តែងតែព្រះសណ្តាប់ឮនូវសេចក្តីអធិស្ឋានរបស់យើងដោយសារព្រះគ្រីស្ទ។

**ភីលីព ៤:៦**

កុំខ្វល់ខ្វាយអ្វីឡើយ ចូរទូលដល់ព្រះ ឲ្យជ្រាបពីសំណូមរបស់អ្នករាល់គ្នាក្នុងគ្រប់ការទាំងអស់ ដោយសេចក្ដីអធិស្ឋាន និងពាក្យទូលអង្វរ ទាំងពោលពាក្យអរព្រះគុណផង (គកស)។

សំណួរទី៤០

# តើយើងគួរតែអធិស្ឋានអំពីអ្វីខ្លះ?



## ចម្លើយ៖

គ្រប់ទាំងព្រះបន្ទូលរបស់ព្រះជាម្ចាស់ណែនាំ និងបណ្តាលចិត្តយើងអំពីអ្វីដែលយើងគួរអធិស្ឋាន ដែលមានរួមទាំងការអធិស្ឋានដែលព្រះយេស៊ូវផ្ទាល់បានបង្រៀនដល់យើងផង។

**អេភេសូរ ៣:១៤-២១**

ដោយហេតុនោះបានជាខ្ញុំលុតជង្គង់ នៅចំពោះព្រះវរបិតានៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា ដែលគ្រប់ទាំងគ្រួនៅស្ថានសួគ៌ ហើយនៅផែនដី មាននាមត្រកូលពីទ្រង់មក ដើម្បីឲ្យទ្រង់បានប្រោសប្រទាន ឲ្យអ្នករាល់គ្នាបានព្រះចេស្តា ចម្រើនកម្លាំងនៃមនុស្សខាងក្នុង ដោយសារព្រះវិញ្ញាណទ្រង់ តាមសិរីល្អនៃទ្រង់ដ៏ប្រសើរក្រៃលែង ឲ្យព្រះគ្រីស្ទបានសណ្ឋិតក្នុងចិត្តអ្នករាល់គ្នា ដោយសារសេចក្តីជំនឿ ប្រយោជន៍ឲ្យអ្នករាល់គ្នាបានចាក់ឫស ហើយតាំងមាំមួនក្នុងសេចក្តីស្រឡាញ់ ដើម្បីឲ្យអាចនឹងយល់ជាមួយនឹងពួកបរិសុទ្ធទាំងអស់គ្នា ពីទទឹង បណ្តោយ ជម្រៅ និងកំពស់នៃសេចក្តីស្រឡាញ់នោះ ហើយឲ្យបានស្គាល់សេចក្តីស្រឡាញ់របស់ព្រះគ្រីស្ទដ៏រកគិតមិនយល់ ប្រយោជន៍ឲ្យអ្នករាល់គ្នាបានពេញដល់គ្រប់ទាំងសេចក្តីពោរពេញរបស់ផងព្រះ។ ឯព្រះដែលទ្រង់អាចនឹងធ្វើហួសសន្ធឹក លើសជាងអស់ទាំងសេចក្តីដែលយើងសូម ឬគិតក្តី តាមព្រះចេស្តាដែលបណ្តាលក្នុងយើងរាល់គ្នា នោះសូមឲ្យទ្រង់បានសិរីល្អ នៅក្នុងពួកជំនុំ ដោយសារព្រះគ្រីស្ទយេស៊ូវ រហូតដល់គ្រប់ទាំងតំណមនុស្ស នៅអស់កល្បជានិច្ចរៀងរាបតទៅ។ អាម៉ែន។

សំណួរទី៤១

# តើអ្វីទៅជាសេចក្តីអធិស្ឋានរបស់ព្រះអម្ចាស់យេស៊ូវ?



ចម្លើយ៖

«ឱ! ព្រះវរបិតានៃយើងខ្ញុំ ដែលគង់នៅស្ថានសួគ៌អើយ! សូមឲ្យព្រះនាមព្រះអង្គបាន បរិសុទ្ធ។ សូមឲ្យព្រះរាជ្យរបស់ ព្រះអង្គបានមកដល់។ សូម ឲ្យព្រះហឫទ័យព្រះអង្គបាន សម្រេចនៅផែនដី ដូចនៅ ស្ថានសួគ៌ដែរ។ សូមប្រទាន អាហារដែលយើងខ្ញុំត្រូវការនៅ ថ្ងៃនេះ។ សូមអត់ទោសកំហុស របស់យើងខ្ញុំ ដូចយើងខ្ញុំបាន អត់ទោសដល់អស់អ្នកដែល ធ្វើខុសនឹងយើងខ្ញុំដែរ។ សូមកុំ នាំយើងខ្ញុំទៅក្នុងសេចក្ដីល្បួង ឡើយ តែសូមប្រោសយើងខ្ញុំឲ្យ រួចពីអាកំណាចវិញ។»

**ម៉ាថាយ ៦:៩**

ដូច្នេះ ចូរអធិស្ឋានបែបយ៉ាងនេះថា ឱព្រះវរបិតា នៃយើងខ្ញុំ ដែលគង់នៅស្ថានសួគ៌អើយ សូមឲ្យ ព្រះនាមព្រះអង្គបានបរិសុទ្ធ.... (គកស)។

សំណួរទី៤២

# តើយើងត្រូវតែអាន និងស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ដោយរបៀបណា?

## ចម្លើយ៖

យើងត្រូវធ្វើដោយយកចិត្តទុកដាក់ មានការត្រៀមចិត្តគំនិតនិងការអធិស្ឋាន ដើម្បីឲ្យយើងអាចទទួលយកដោយជំនឿដាក់ទុកក្នុងដួងចិត្ត ហើយនិងអនុវត្តនៅក្នុងជីវិតរស់នៅរបស់យើង។

**២ធីម៉ូថេ ៣:១៦-១៧**

គ្រប់ទាំងបទគម្ពីរ ព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្ដាលឲ្យតែង ហើយមានប្រយោជន៍សម្រាប់ការបង្រៀន ការរំឭកឲ្យដឹងខ្លួន ការកែតម្រង់ និងការបង្ហាត់ខាងឯសេចក្ដីសុចរិត ដើម្បីឲ្យអ្នកសំណព្វរបស់ព្រះបានគ្រប់លក្ខណ៍ ហើយមានចំណេះសម្រាប់ធ្វើការល្អគ្រប់ជំពូក (គកស)។

សំណួរទី៤៣

# តើពិធីបង្គ្រព្រះគុណ ឬបទបញ្ញត្តិមានអ្វីខ្លះ?



ចម្លើយ៖

ពិធីបង្ហូរព្រះគុណ ឬបទបញ្ញត្តិ ដែលព្រះជាម្ចាស់បានប្រទានមក ហើយដែលព្រះគ្រីស្ទបានតាំងឡើងមានពិធីជ្រមុជទឹក និងពិធីលៀងព្រះអម្ចាស់។ ពិធីទាំងពីរនេះគឺជាទីសម្គាល់ និងជាត្រាដៅចំណាំដែលយើងអាចមើលឃើញនឹងភ្នែកដែលបញ្ជាក់ថា យើងបានរួមគ្នាមកជាសហគមន៍នៃជំនឿតាមរយៈការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រីស្ទ។ តាមរយៈការប្រើប្រាស់ទីសម្គាល់ទាំងនេះ នោះព្រះវិញ្ញាណបរិសុទ្ធប្រកាស និងដៅត្រាចំណាំកាន់តែពេញលេញនូវសេចក្តីសន្យានៃដំណឹងល្អដល់យើង។

**រ៉ូម ៦:៤**

ដូច្នេះ យើងបានត្រូវកប់ជាមួយនឹងទ្រង់ហើយ ដោយទទួលជ្រមុជក្នុងសេចក្តីស្លាប់ ដើម្បីឲ្យយើងបានដើរក្នុងជីវិតបែបថ្មី ដូចជាព្រះគ្រីស្ទបានរស់ពីស្លាប់ឡើងវិញ ដោយសារសិរីល្អនៃព្រះវរបិតាដែរ។

**លូកា ២២:១៩-២០**

រួចទ្រង់ក៏យកនំបុ័ងមកអរព្រះគុណ ហើយកាច់ប្រទានទៅគេ ដោយបន្ទូលថា «នេះហើយជារូបកាយខ្ញុំ ដែលបានប្រទានមកសំរាប់អ្នករាល់គ្នា ចូរធ្វើបុណ្យនេះ ដើម្បីរំឭកពីខ្ញុំចុះ» ក្រោយដែលបានបរិភោគហើយ នោះទ្រង់យកពែងមកធ្វើបែបដូច្នោះដែរ ដោយបន្ទូលថា «ពែងនេះជាសញ្ញាថ្មី ដែលតាំងដោយនូវឈាមខ្ញុំ គឺជាឈាមដែលត្រូវច្រួចចេញសំរាប់អ្នករាល់គ្នា»។

សំណួរទី៤៤

# តើអ្វីទៅជាពិធីជ្រមុជទឹក?



ចម្លើយ៖

ពិធីជ្រមុជទឹកគឺជាការលាងដោយទឹកនៅក្នុងព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ។ វាជាទីសម្គាល់ និងត្រាបញ្ជាក់ថាយើងបានក្លាយជាបុត្រាបុត្រីចិញ្ចឹមរបស់ព្រះក្នុងព្រះគ្រីស្ទ ហើយថាយើងបានទទួលនូវការលាងសម្អាតចេញពីអំពើបាប ព្រមទាំងថាយើងបានប្ដេជ្ញាចិត្តធ្វើជាកម្មសិទ្ធិរបស់ព្រះអម្ចាស់ និងក្រុមជំនុំរបស់ទ្រង់។

**ម៉ាថាយ ២៨:១៩**

ដូច្នេះ ចូរទៅបង្កើតឲ្យមានសិស្សនៅគ្រប់ទាំងសាសន៍ ព្រមទាំងធ្វើពិធីជ្រមុជទឹកឲ្យគេ ក្នុងព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ.... (គកស)។

សំណួរទី៤៥

# តើទឹកនៅក្នុងពិធីជ្រមុជទឹកលាងសម្អាតនូវអំពើបាបមែនឬ?

## ចម្លើយ៖

ទេ! មានតែតាមរយៈព្រះលោហិតរបស់ព្រះគ្រីស្ទទេ និងការកើតជាថ្មីដោយព្រះវិញ្ញាណបរិសុទ្ធតែប៉ុណ្ណោះទើបអាចសម្អាតយើងឲ្យស្អាតចេញពីអំពើបាបបាន។

**លូកា ៣:១៦**

នោះយ៉ូហានប្រាប់គេគ្រប់គ្នាថា៖ «ខ្ញុំធ្វើពិធីជ្រមុជឲ្យអ្នករាល់គ្នាដោយទឹក ប៉ុន្តែ មានព្រះមួយអង្គដែលមានអំណាចខ្លាំងជាងខ្ញុំ ជិតមកដល់ហើយ ខ្ញុំមិនស័ក្តិសមនឹងស្រាយខ្សែសុព័ណ៌បាទព្រះអង្គផង។ ព្រះអង្គនឹងធ្វើពិធីជ្រមុជឲ្យអ្នករាល់គ្នា ដោយព្រះវិញ្ញាណបរិសុទ្ធ និងដោយភ្លើងវិញ» (គកស)។

សំណួរទី៤៦

# តើអ្វីទៅជាពិធីលៀងព្រះអម្ចាស់?



ចម្លើយ៖

ព្រះគ្រីស្ទបានបង្គាប់ឲ្យគ្រីស្ទបរិស័ទទាំងអស់ទទួលទាននំបុ័ង និងផឹកពីពែងទាំងនឹកចាំពីទ្រង់ និងការសុគតរបស់ទ្រង់ដោយអរព្រះគុណ។ ពិធីលៀងព្រះអម្ចាស់គឺជាការអបអរសាទរអំពីព្រះវត្តមានរបស់ព្រះជាម្ចាស់ដែលគង់នៅកណ្ដាលចំណោមយើង នាំឲ្យយើងមានការប្រកបគ្នាជាមួយព្រះ និងជាមួយគ្នាទៅវិញទៅមក ព្រមទាំងចម្អែត និងចិញ្ចឹមព្រលឹងវិញ្ញាណរបស់យើងដែរ។ វាក៏ជាការទន្ទឹងរង់ចាំថ្ងៃដែលយើងនឹងទទួលទាន ហើយផឹកជាមួយព្រះគ្រីស្ទនៅក្នុងនគរនៃព្រះវរបិតាទ្រង់ផងដែរ។

**១កូរិនថូស ១១:២៣-២៦**

ដ្បិតសេចក្ដីដែលខ្ញុំបានបង្រៀនអ្នករាល់គ្នា នោះខ្ញុំបានទទួលពីព្រះអម្ចាស់មកថា នៅយប់ដែលព្រះអម្ចាស់យេស៊ូវត្រូវគេបញ្ជូន ទ្រង់បានយកនំបុ័ងមក លុះទ្រង់បានអរព្រះគុណរួចហើយ ទ្រង់ក៏កាច់នំបុ័ង ហើយមានព្រះបន្ទូលថា៖ «នេះជារូបកាយខ្ញុំដែលត្រូវបូជាសម្រាប់អ្នករាល់គ្នា ចូរធ្វើដូច្នេះទុកជាការរំឭកពីខ្ញុំ»។ ក្រោយពីបរិភោគរួចហើយ ព្រះអង្គក៏យកពែងធ្វើបែបដូច្នោះដែរ ដោយមានព្រះបន្ទូលថា៖ «ពែងនេះជាសញ្ញាថ្មី តាំងឡើងដោយឈាមរបស់ខ្ញុំ។ ចូរធ្វើដូច្នេះរាល់ពេលដែលអ្នករាល់គ្នាផឹកដើម្បីរំឭកពីខ្ញុំ»។ ដ្បិតរាល់ពេលដែលអ្នករាល់គ្នាបរិភោគនំបុ័ងនេះ ហើយផឹកពីពែងនេះ នោះអ្នករាល់គ្នាប្រកាសពីការសុគតរបស់ព្រះអម្ចាស់ រហូតដល់ព្រះអង្គយាងមក។

សំណួរទី៤៧

# តើពិធីលៀងព្រះអម្ចាស់មានបន្ថែមអ្វីដល់យញ្ញបូជាធួននឹងបាបរបស់ព្រះគ្រីស្ទដែរឬទេ?



ចម្លើយ៖

ទេ! ព្រះគ្រីស្ទបានសុគតម្តង ហើយសម្រេចសព្វគ្រប់សម្រាប់ទាំងអស់។ ពិធីលៀងព្រះអម្ចាស់គឺជាការទទួលទានអាហារសម្ពន្ធមេត្រីអបអរសាទរចំពោះយញ្ញបូជាធួននឹងបាបរបស់ព្រះគ្រីស្ទ ហើយវាក៏ជាពិធីមួយដែលពង្រឹងជំនឿរបស់យើងខណៈពេលដែលយើងសម្លឹងមើលទៅឯទ្រង់ ហើយក៏ជាការភ្លក់មើលពិធីជប់លៀងព្រះអម្ចាស់នៅពេលអនាគតដែរ។ ប៉ុន្តែអស់អ្នកណាដែលចូលរួមចំណែកក្នុងពិធីនេះ ដោយមិនបានប្រែចិត្តនៅឡើយ គឺជាអ្នកដែលបរិភោគ និងផឹកសេចក្តីជំនុំជម្រះលើខ្លួនឯងហើយ។

**១ពេត្រុស ៣:១៨**

ដ្បិតព្រះគ្រីស្ទក៏បានរងទុក្ខម្តងជាសម្រេច ព្រោះតែបាបដែរ គឺព្រះដ៏សុចរិតរងទុក្ខជំនួសមនុស្សទុច្ចរិត ដើម្បីនាំយើងទៅរកព្រះ.... (គកស)។

សំណួរទី៤៨

# តើអ្វីទៅជាក្រុមជំនុំ?



ចម្លើយ៖

ក្រុមជំនុំគឺជាសហគមន៍ដែលព្រះជាម្ចាស់បានជ្រើសរើស និងរក្សាទុកសម្រាប់ទ្រង់ ដើម្បីប្រទានជីវិតអស់កល្បជានិច្ចដល់ពួកគេ។ ពួកគេមានការរួបរួមគ្នាដោយជំនឿ ដែលធ្វើឲ្យពួកគេស្រឡាញ់ទ្រង់ ដើរតាមទ្រង់ រៀនពីទ្រង់ និងថ្វាយបង្គំព្រះអង្គជាមួយគ្នា។ ព្រះជាម្ចាស់ចាត់សហគមន៍នេះឲ្យចេញទៅប្រកាសដំណឹងល្អ និងបង្ហាញអំពីនគររបស់ព្រះគ្រីស្ទដែលនឹងមកដល់ តាមរយៈគុណសម្បត្តិនៃជីវិតរស់នៅរបស់ពួកគេជាមួយគ្នា និងតាមរយៈសេចក្តីស្រឡាញ់របស់ពួកគេចំពោះគ្នាទៅវិញទៅមក។

**២ថែស្សាឡូនីច ២:១៣**

ឱបងប្អូនដ៏ជាស្ងួនភ្ងានៃព្រះអម្ចាស់អើយ យើងខ្ញុំត្រូវតែអរព្រះគុណដល់ព្រះអង្គជានិច្ច ពីដំណើរអ្នករាល់គ្នា ពីព្រោះព្រះទ្រង់បានរើសអ្នករាល់គ្នា តាំងពីដើមដំបូងមក ដើម្បីឲ្យបានសង្គ្រោះ ដោយព្រះវិញ្ញាណទ្រង់ញែកចេញជាបរិសុទ្ធ ហើយដោយមានចិត្តជឿតាមសេចក្តីពិតផង។

សំណួរទី៤៩

# តើឥឡូវនេះព្រះគ្រីស្ទគង់នៅឯណា?

ចម្លើយ៖

ក្រោយពេលទ្រង់សុគត ព្រះគ្រីស្ទបានមានព្រះជន្មរស់ឡើងវិញខាងឯរូបកាយចេញពីផ្នូរនៅថ្ងៃទីបី ហើយឥឡូវនេះកំពុងគង់នៅខាងស្តាំព្រះហស្តព្រះវរបិតា។ ព្រះគ្រីស្ទកំពុងសោយរាជ្យលើនគរទ្រង់ ហើយនិងទូលអង្វរសម្រាប់យើងរហូតដល់ពេលទ្រង់យាងមកវិញ ដើម្បីជំនុំជម្រះ និងបង្កើតផែនដីថ្មីទាំងមូលឡើងវិញ។

**អេភេសូរ ១:២០-២១**

ជាព្រះចេស្តាដែលព្រះអង្គបានសម្តែងចេញ ដោយប្រោសព្រះគ្រីស្ទឲ្យមានព្រះជន្មរស់ពីស្លាប់ឡើងវិញ ហើយតាំងឲ្យគង់ខាងស្តាំព្រះអង្គនៅស្ថានសួគ៌ ឲ្យខ្ពស់ជាងអស់ទាំងពួកគ្រប់គ្រង ពួកមានអំណាច មានឫទ្ធិបារមី និងពួកមេទាំងប៉ុន្មាន ហើយគ្រប់ទាំងឈ្មោះដែលបានតាំងឡើងដែរ មិនមែនតែក្នុងសម័យនេះប៉ុណ្ណោះ តែនៅឯបរលោកផងដែរ (គកស)។

សំណួរទី៥០

# តើការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រីស្ទមានន័យយ៉ាងដូចម្តេចសម្រាប់យើង?



ចម្លើយ៖

តាមរយៈការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រីស្ទខាងឯរូបកាយ ទ្រង់បានមានជ័យជម្នះលើអំពើបាប និងសេចក្ដីស្លាប់ ដើម្បីឲ្យអស់អ្នកដែលទុកចិត្តលើទ្រង់បានទទួលនូវការប្រោសឲ្យរស់ឡើងវិញនៅក្នុងជីវិតលើផែនដីនេះ និងនៅក្នុងជីវិតអស់កល្បជានិច្ចលើផែនដីថ្មីដែលនឹងមកដល់។

ដូចដែលនឹងមានថ្ងៃមួយដែលព្រះជាម្ចាស់នឹងប្រោសយើងឲ្យមានជីវិតរស់ឡើងវិញពីស្លាប់ ក៏នឹងមានថ្ងៃមួយដែលព្រះអង្គនឹងស្តារផែនដីនេះឡើងវិញផងដែរ។ ប៉ុន្តែ អស់អ្នកណាដែលមិនជឿទុកចិត្តលើព្រះគ្រីស្ទ ពួកគេនឹងរស់ឡើងវិញ ដើម្បីទទួលសេចក្ដីស្លាប់ដ៏នៅអស់កល្បជានិច្ច។

**១ថែស្សាឡូនីច ៤:១៣-១៤**

បងប្អូនអើយ ខ្ញុំមិនចង់ឲ្យអ្នករាល់គ្នាឥតដឹង ពីពួកអ្នកដែលដេកលក់ទៅហើយទេ ក្រែងអ្នករាល់គ្នាកើតទុក្ខព្រួយ ដូចជាអ្នកឯទៀត ដែលគ្មានសង្ឃឹម ដ្បិតបើយើងជឿថា ព្រះយេស៊ូវបានសុគត ព្រមទាំងរស់ឡើងវិញហើយ នោះត្រូវជឿថា ព្រះទ្រង់នឹងនាំអស់អ្នកដែលដេកលក់ទៅក្នុងព្រះយេស៊ូវ ឲ្យបានមកជាមួយនឹងទ្រង់ដែរ។

សំណួរទី៥១

# តើការដែលព្រះគ្រីស្ទយាងឡើងទៅឯស្ថានសួគ៌វិញមានប្រយោជន៍អ្វីខ្លះដល់យើង?



## ចម្លើយ៖

ព្រះគ្រីស្ទបានយាងឡើងទៅឯស្ថានសួគ៌វិញ ខាងឯរូបកាយសម្រាប់យើង ដូចដែលទ្រង់បានយាងចុះមកលើផែនដី ដើម្បីយកនិស្ស័យជាមនុស្សសម្រាប់យើងដែរ។ ហើយឥឡូវនេះ ព្រះអង្គកំពុងតែទូលអង្វរសម្រាប់យើងនៅចំពោះព្រះវត្តមានរបស់ព្រះវរបិតាទ្រង់ ហើយកំពុងតែរៀបចំកន្លែងមួយសម្រាប់យើង ព្រមទាំងចាត់ព្រះវិញ្ញាណទ្រង់មកឯយើងផងដែរ។

**រ៉ូម ៨:៣៤**

តើអ្នកណាអាចកាត់ទោសគេបាន? ដ្បិតគឺព្រះគ្រីស្ទយេស៊ូវហើយដែលបានសុគត មែនហើយ! ព្រះអង្គមានព្រះជន្មរស់ឡើងវិញ ព្រះអង្គគង់នៅខាងស្ដាំព្រះហស្តរបស់ព្រះ គឺព្រះអង្គហើយជាអ្នកទូលអង្វរឲ្យយើង (គកស)។

សំណួរទី៥២

# តើជីវិតអស់កល្បជានិច្ចផ្តល់នូវសង្ឃឹមដល់យើងយ៉ាងដូចម្តេចខ្លះ?



ចម្លើយ៖

វារម្លឹកយើងថា ផែនដីដែលបានធ្លាក់ទៅក្នុងអំពើបាបនាពេលបច្ចុប្បន្ននេះនឹងមិននៅបែបនេះជារៀងរហូតនោះទេ។ នាពេលឆាប់ៗនេះ យើងនឹងរស់នៅជាមួយនឹងព្រះជាម្ចាស់ ហើយមានអំណរជាមួយនឹងទ្រង់យ៉ាងអស់កល្បជានិច្ចនៅក្នុងទីក្រុងថ្មី គឺនៅឯផ្ទៃមេឃថ្មី និងផែនដីថ្មី ដែលជាទីកន្លែងដែលយើងនឹងទទួលបាននូវសេរីភាពយ៉ាងពេញលេញរួចចេញពីអំពើបាបទាំងអស់ជារៀងដរាបតទៅ។ នៅពេលនោះ ព្រះអង្គនឹងប្រោសយើងឲ្យរស់ឡើងវិញ ហើយប្រទាននូវរូបកាយថ្មីដល់យើងនៅក្នុងការបង្កើត និងការស្តាររបស់សព្វសារពើឡើងវិញជាថ្មី។

**វិវរណៈ ២១:១-៤**

រួចខ្ញុំឃើញផ្ទៃមេឃថ្មី និងផែនដីថ្មី ដ្បិតផ្ទៃមេឃមុន និងផែនដីមុនបានកន្លងបាត់ទៅហើយ ក៏គ្មានសមុទ្រទៀតឡើយ ហើយយ៉ូហានខ្ញុំ ក៏ឃើញទីក្រុងដ៏បរិសុទ្ធ គឺជាក្រុងយេរូសាឡឹមថ្មី ចុះពីស្ថានសួគ៌មកអំពីព្រះ តាក់តែងដូចជាប្រពន្ធថ្មោងថ្មីតែងខ្លួនទទួលប្ដី ខ្ញុំមានឮសំឡេង១យ៉ាងខ្លាំង ចេញពីស្ថានសួគ៌មកថា «មើលរោងឧបោសថរបស់ព្រះ បាននៅជាមួយនឹងមនុស្សហើយ ទ្រង់នឹងគង់នៅជាមួយនឹងគេ គេនឹងធ្វើជារាស្ត្ររបស់ទ្រង់ ហើយព្រះអង្គទ្រង់ក៏នឹងធ្វើជាព្រះដល់គេ»។

# ការរម្លឹក

ការសរសេរគឺជាជំនួយមួយក្នុង
ការជួយឲ្យចងចាំ។ សូមប្រើប្រាស់
កន្លែងនេះសម្រាប់ជាការរម្លឹក
ដោយសរសេរនូវចម្លើយសម្រាប់
សំណួរនីមួយៗ ហើយបន្ទាប់មក
ឆែកមើលជាមួយនឹងសៀវភៅ។

## ផ្នែកទី១ – ព្រះជាម្ចាស់
## ការបង្កើតពិភពលោក
## ការធ្លាក់ក្នុងអំពើបាប
## និងក្រឹត្យវិន័យ

១. តើអ្វីទៅជាក្ដីសង្ឃឹមតែមួយគត់របស់យើងនៅក្នុងជីវិតនេះ និងនៅពេលដែលយើងស្លាប់ទៅ?

២. តើព្រះជានរណា?

៣. តើក្នុងព្រះមានបុគ្គលប៉ុន្មានអង្គ?

៤. តើព្រះបានបង្កើតមនុស្សយ៉ាងដូចម្ដេច និងក្នុងគោលបំណងអ្វី?

៥. តើព្រះបានបង្កើតអ្វីផ្សេងទៀតមក?

៦. តើយើងអាចថ្វាយសិរីល្អដល់ព្រះជាម្ចាស់បានដោយរបៀបណា?

៧. តើក្រឹត្យវិន័យរបស់ព្រះជាម្ចាស់ទាមទារអ្វីខ្លះ?

៨. តើក្រឹត្យវិន័យទាំងដប់ប្រការរបស់ព្រះជាម្ចាស់មានចែងឡើងយ៉ាងដូចម្ដេចខ្លះ?

៩. តើព្រះជាម្ចាស់ទាមទារឲ្យយើងធ្វើអ្វីខ្លះនៅក្នុងក្រឹត្យវិន័យទី១ ទី២ និងទី៣?

១០. តើព្រះជាម្ចាស់ទាមទារឲ្យយើងធ្វើអ្វីខ្លះនៅក្នុងក្រឹត្យវិន័យទី៤ និងទី៥?

១១. តើព្រះជាម្ចាស់ទាមទារឲ្យយើងធ្វើអ្វីខ្លះនៅក្នុងក្រឹត្យវិន័យទី៦ ទី៧ និងទី៨?

១២. តើព្រះជាម្ចាស់ទាមទារឲ្យយើងធ្វើអ្វីខ្លះនៅក្នុងក្រឹត្យវិន័យទី៩ និងទី១០?

១៣. តើមានអ្នកណាម្នាក់អាចប្រតិបត្តិតាមក្រឹត្យវិន័យរបស់ព្រះជាម្ចាស់បានយ៉ាងល្អឥតខ្ចោះដែរឬទេ?

១៤. តើព្រះជាម្ចាស់បានបង្កើតយើងមកឲ្យគ្មានសមត្ថភាពក្នុងការប្រតិបត្តិតាមក្រឹត្យវិន័យរបស់ទ្រង់មែនឬ?

១៥. តើអ្វីទៅជាគោលបំណងរបស់ក្រឹត្យវិន័យ បើគ្មានអ្នកណាម្នាក់អាចប្រតិបត្តិតាមបានផង?

១៦. តើអ្វីទៅជាអំពើបាប?

១៧. តើអ្វីទៅជាការថ្វាយបង្គំរូបព្រះក្លែងក្លាយ?

១៨. តើព្រះជាម្ចាស់នឹងមិនដាក់ទោសចំពោះការមិនស្ដាប់បង្គាប់ និងការថ្វាយបង្គំរូបព្រះក្លែងក្លាយរបស់យើងទេឬអី?

១៩. តើមានមធ្យោបាយណាមួយដែលអាចនាំឲ្យយើងគេចផុតពីការដាក់ទោសរបស់ព្រះ ហើយនាំឲ្យយើងជានាជាមួយព្រះអង្គវិញបានទេ?

២០. តើអ្នកណាទៅជាព្រះដ៏ប្រោសលោះនោះ?

## ផ្នែកទី២ – ព្រះគ្រីស្ទ ការប្រោសលោះ និងព្រះគុណ

២១. តើយើងត្រូវការព្រះដ៏ប្រោសលោះដែលមានលក្ខណៈយ៉ាងដូចម្ដេចដើម្បីនាំយើងទៅកាន់ព្រះជាម្ចាស់វិញ?

២២. ហេតុអ្វីបានជាព្រះដ៏ប្រោសលោះត្រូវតែជាមនុស្ស ១០០%?

២៣. ហេតុអ្វីបានជាព្រះដ៏ប្រោសលោះត្រូវតែជាព្រះ ១០០%?

២៤. ហេតុអ្វីបានជាព្រះគ្រីស្ទដែលជាព្រះដ៏ប្រោសលោះចាំបាច់ត្រូវសុគត?

២៥. តើការសុគតរបស់ព្រះគ្រីស្ទមានន័យថាយើងអាចទទួលបានការអត់ទោសចំពោះអំពើបាបទាំងអស់របស់យើងមែនឬ?

២៦. តើការសុគតរបស់ព្រះគ្រីស្ទបានប្រោសលោះអ្វីផ្សេងទៀត?

២៧. តើមនុស្សទាំងអស់ក៏នឹងបានសេចក្ដីសង្គ្រោះតាមរយៈព្រះគ្រីស្ទ ដូចដែលមនុស្សទាំងអស់បានបាត់បង់តាមរយៈលោក អ័ដាមដែរមែនឬ?

២៨. ក្រោយពីស្លាប់ទៅ តើនឹងមានអ្វីកើតឡើងចំពោះអស់អ្នកដែលមិនបានរួបរួមជាមួយនឹងព្រះគ្រីស្ទតាមរយៈជំនឿ?

២៩. តើយើងអាចទទួលបានសេចក្ដីសង្គ្រោះយ៉ាងដូចម្ដេច?

៣០. តើអ្វីទៅជាជំនឿលើព្រះយេស៊ូវគ្រីស្ទ?

៣១. នៅក្នុងជំនឿដ៏ពិត តើយើងជឿលើអ្វីខ្លះ?

៣២. តើការរាប់ជាសុចរិត និងការញែកជាបរិសុទ្ធមានន័យយ៉ាងដូចម្ដេច?

៣៣. តើគួរឲ្យអស់អ្នកដែលមានជំនឿលើព្រះគ្រីស្ទរួចហើយស្វែងរកសេចក្ដីសង្គ្រោះដោយពឹងលើការប្រព្រឹត្តរបស់ខ្លួនឯង ឬពីកន្លែងណាផ្សេងទៀត?

៣៤. ដោយសារព្រះបានប្រោសលោះយើងដោយព្រះគុណតាមរយៈព្រះគ្រីស្ទតែមួយគត់ តើយើងនៅតែត្រូវប្រព្រឹត្តអំពើល្អ និងស្ដាប់បង្គាប់តាមព្រះបន្ទូលព្រះដែរឬទេ?

៣៥. ដោយសារព្រះបានប្រោសលោះយើងដោយព្រះគុណតែប៉ុណ្ណោះតាមរយៈជំនឿតែមួយគត់ តើជំនឿនេះកើតមកពីណា?

## ផ្នែកទី៣ – ព្រះវិញ្ញាណ
## ការស្ដារឡើងវិញ និងការរីកចម្រើនក្នុងព្រះគុណ

៣៦. តើយើងជឿអ្វីខ្លះអំពីព្រះវិញ្ញាណបរិសុទ្ធ?

៣៧. តើព្រះវិញ្ញាណបរិសុទ្ធជួយយើងដោយរបៀបណាខ្លះ?

៣៨. តើអ្វីទៅជាការអធិស្ឋាន?

៣៩. តើយើងគួរអធិស្ឋានដោយមានអាកប្បកិរិយាបែបណាទៅ?

៤០. តើយើងគួរតែអធិស្ឋានអំពីអ្វីខ្លះ?

៤១. តើអ្វីទៅជាសេចក្ដីអធិស្ឋានរបស់ព្រះអម្ចាស់យេស៊ូវ?

៤២. តើយើងត្រូវតែអាន និងស្ដាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ដោយរបៀបណា?

៤៣. តើពិធីបង្ហូរព្រះគុណ ឬបទបញ្ញត្តិមានអ្វីខ្លះ?

៤៤. តើអ្វីទៅជាពិធីជ្រមុជទឹក?

៤៥. តើទឹកនៅក្នុងពិធីជ្រមុជទឹកលាងសម្អាតនូវអំពើបាបមែនឬ?

៤៦. តើអ្វីទៅជាពិធីលៀងព្រះអម្ចាស់?

៤៧. តើពិធីលៀងព្រះអម្ចាស់មានបន្ថែមអ្វីដល់យញ្ញបូជាធួននឹងបាបរបស់ព្រះគ្រីស្ទដែរឬទេ?

៤៨. តើអ្វីទៅជាក្រុមជំនុំ?

៤៩. តើឥឡូវនេះព្រះគ្រីស្ទគង់នៅឯណា?

៥០. តើការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រីស្ទមានន័យយ៉ាងដូចម្ដេចសម្រាប់យើង?

៥១. តើការដែលព្រះគ្រីស្ទយាងឡើងទៅឯស្ថានសួគ៌វិញមានប្រយោជន៍អ្វីខ្លះដល់យើង?

៥២. តើជីវិតអស់កល្បជានិច្ចផ្ដល់នូវសង្ឃឹមដល់យើងយ៉ាងដូចម្ដេចខ្លះ?

សូមចូលទៅកាន់គេហទំព័រ
www.khmerqanda.com ដើម្បីរក
ឃើញធនធានមួយចំនួនទៀត។